# កម្ពុជសុរិយា

ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MŒURS & COUTUMES

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រៈ ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនាៈ ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកត្រួតត្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង


### ផ្នែកអក្សរសាស្ត្រ

| | | ទំព័រ |
|---|---|---|
| ឃុនឧត្តមប្រីជា ជាប-ពិន . . . | ប្រស្នាត្រៃមន្ត្រី . . . . . . . . . . . . | ៣៣៩ |
| លោក ហាន់-យេង . . . . . . | រឿងកំពូលកំសត់ (តមក) . . . . . . . . | ៣៤៩ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . | ប្រជុំសុភាសិតខ្មែរ តាមលំដាប់អក្សរ (តមក) | ៣៦០ |
| លោក ញ៉ុក-នូ . . . . . . | ច្បាប់ក្រមបរិយាយ (តមក) . . . . . . . | ៣៦៥ |
| ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៊ុណ្ណ | សុវណ្ណសាមជាតក ពាក្យកាព្យ (តមក) . . | ៣៧៣ |

### ផ្នែកសាសនា

| | | |
|---|---|---|
| ព្រះគ្រូសុវណ្ណញាណ ស្វរ-ហាយ. | បរិយាយសិប្បកថា (តមក) . . . . . . . | ៣៨០ |
| ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . | ឯកភាគ នៃមិលិន្ទបញ្ហា (តមក) . . . . | ៣៨៦ |


ឆ្នាំទី ១៦ — លេខ ៧ ខែអស្សុជ ឆ្នាំ ១៩៤៤ — ថ្លៃប្រចាំៈ ១ ឆ្នាំ ១៥ រៀល ។

M.S 1461

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire : Luong Nibandhamantri NHOK-THÊM, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse : Preah kru Paññalikhito KAO-SIM, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

### Partie littéraire :


| | | Pages |
|---|---|---|
| K'ŭn Ŏtdămpreichea Chap-Pinn . . . . . . | Prâsna Trăimontrei . . . . . . . | 339 |
| Monsieur Han-Yéng . . . . | Kămpul kămsăt, roman (suite) . . | 349 |
| Luong nĭponmontrei Nhok-Thêm. . . . . . | Recueil de proverbes cambodgiens classés par ordre alphabétique (suite) . . . . . . . . . . . | 360 |
| Monsieur Nheuk-Nou. . . . | Chbáp krămborĭyay (suite). . . . . | 365 |
| Prĕah sămŭk'ósachar You-Ponn . . . . . . | Suvannasāmajātaka, poème (suite) | 373 |


### Partie religieuse :


| | | |
|---|---|---|
| Prĕah kru Suvaddhañāna So-Hay. . . . . . . . | Pariyāyasippakathā (suite). . . . | 380 |
| Luong Nĭponmontrei Nhok-Thêm. . . . . . | Ekabhāga Milindapañhā (suite) . . | 386 |


16e année — No 7. Juillet 1944 — Abonnement : un an 15$00.

# ប្រស្នាត្រៃមន្ត្រី

## របស់ ឃុនឧត្តមប្រីជា ចាប-ពិន

### ក្រុមពុទ្ធសាសនបណ្ឌិត្យ

វេលាមួយ ជាវេលាចូលឆ្នាំខ្មែរ, អស់ពួកមន្ត្រីរាជការគ្រប់កំណែង បានព្រះរាជានុញ្ញាតឈប់សម្រាក ៣ ថ្ងៃ ដើម្បីធ្វើបុណ្យចូលឆ្នាំថ្មីតាមទំនៀមស្រុក ៗ ឱកាសនោះ ក្នុងផ្ទះឧកញ៉ាឧត្តមសម្បត្តិ នៅក្រុងភ្នំពេញ មានកិច្ចធ្វើកុសលានុប្បទានឧទ្ទិសផលជូនលោកអ្នកមានគុណដែលធ្វើមរណកាល, បានរៀបចំភាក់តែងតុតាំងកៅអី កម្រាលព្រែព្រំបៀមចំក្បាច់ផ្កាជាច្រើន, និមន្តព្រះសង្ឃជាច្រើនរូបមកទទួលភត្ត ៗ មានអស់លោកមន្ត្រី និងពួកឧបាសកឧបាសិកា ជាញាតិមិត្រនៅជិតខាង មកជួយចាត់ចែងជាច្រើន ៗ .

វេលាវេរភត្តឧទ្ទិសផលរួចសព្វគ្រប់ ប្រគេនបង្ហាន់ព្រះសង្ឃ, ព្រះសង្ឃកំពុងឆាន់ដោយរៀបរយ; ក្នុងវេលានោះ, ហ្លួងប្រជានុសិដ្ឋ ផ្ដើមនិយាយសំណេះសំណាលប្រកបក្បួនច្បាប់នឹងឃុនអាករកោសលថា: យើងទាំងអស់គ្នាជាឃរាវាសដែលមានកូនប្រុសស្រី សុទ្ធតែត្រូវរៀបចំឲ្យមានគូស្រករតែរៀងខ្លួន, ចំណែកខាងលោក បើនឹងរៀបកូនស្រីឲ្យមានស្វាមី តើលោកចូលចិត្តឲ្យទៅមនុស្សបែបណា ?

ប្រស្នានេះខ្ញុំបាទពិបាកដំរូបណាស់លោក! មិនងាយទេ, ព្រោះគំនិតមនុស្សយើងដែលប៉ុនប្រាជ្ញា ជួនកាលក៏បានសម្រេច ជួនកាលមិនបានសម្រេចដូចបំណងទេ ។ យុនរ៉ៅហារកោសល តប.

បាទ, ដែលលោកមានប្រសាសន៍ថាពិបាក នោះពិតណាស់ហើយ, ប៉ុន្តែទោះបីពិបាកយ៉ាងម៉េច ក៏យើងត្រូវតែគិត ខានពុំបាន, បើយើងមិនគិតសោះ បេះតែឲ្យដោយប្រថុយប្រថានទៅ ក៏មិនកើតដែរ, ក្រែងដល់ទៅថ្ងៃខាងមុខ កើតសេចក្ដីមិនស្រួលដល់កូនស្រីយើង; តែកើតរឿងមិនស្រួលឡើង កូនស្រីយើងក៏បន្ទោសយើងបាន, ព្រោះហេតុនេះ បានជាមានពុកណាសុភាសិតថា "ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅ មើលផៅសន្តាន" ។ ចំណែកខ្ញុំបាទរើសបន្តិចហើយ មិនងាយប្រថុយទេ ខាងលោកតើរើសយ៉ាងណា ឬលោកមិនរើសទេ ? ហ្លួងប្រជានុសិដ្ឋសូរ.

ខ្ញុំបាទក៏រើសដូចលោកដែរ មិនមែនបេះតែប្រថុយទេ, តែការនេះស្រេចលើសំណាងកូនខ្ញុំបាទផង ដ្បិតបុរាណលោកពោលថា "នាងត្រូវនឹងអ្នក មេខាតលក្ខណ៍ត្រូវនឹងអាក់បាក់ទន្សា, គូគេចមិនរួច អាយុមិនអស់មិនស្លាប់"; ព្រោះសំណាងកូនខ្ញុំបាទមិនដឹងជាដូចម្ដេចដែរ, ខ្ញុំបាទជាអាពុកគ្រាន់តែជួយជ្រប៉ុណ្ណោះ ។ យុនរ៉ៅហារកោសល តប.

នៅឱកាសដែលមន្ត្រីពីរនាក់ កំពុងប្រឹក្សាគ្នាមិនទាន់ដាច់ស្រេច, ស្រាប់តែឧកញ៉ាធម្មានុសាសក៍ ជាមន្ត្រីក្រមការបណ្ឌិត ចូលមកអង្គុយក្នុងទីប្រជុំនោះដែរ, ហ្លួងប្រជានុសិដ្ឋ ក៏ងាកទៅប្រឹក្សានឹងឧកញ៉ាធម្មានុសាសក៍ថា: ឱ ! ដំណើរដែលលោកអញ្ជើញមកនេះជាការប្រពៃណាស់, ព្រោះខ្ញុំបាទជាមួយនឹងឃុនវោហារកោសល កំពុងពិភាក្សាគ្នាពីរឿងរៀបចំកូនចៅឲ្យមានគូស្រករ មិនទាន់ដាច់ស្រេច; សូមលោកជាអ្នកប្រាជ្ញជួយវិនិច្ឆ័យសេចក្តីនេះឲ្យត្រឹមត្រូវផង, មើលទៅលោក! ព្រះសម្មាសម្ពុទ្ធជាបរមគ្រូរបស់យើង ទ្រង់បានសំដែងពីរឿងរៀបចំកូនស្រីឲ្យមានស្វាមីដែរឬទេ ?

ព្រះសម្មាសម្ពុទ្ធឥតមានបារៈ ក្នុងរឿងរៀបចំកូនចៅឲ្យមានគូស្រករទេ, ព្រះអង្គមានព្រះអធ្យាស្រ័យតែខាងចម្លងសត្វឲ្យឆ្លងកាត់វាលវដ្តសង្សារទៅកាន់ឋានព្រះនិព្វានតែមួយយ៉ាងទេតើលោក! ។ ឧកញ៉ាធម្មានុសាសក៍តប .

បាទ, ព្រះពុទ្ធជាម្ចាស់ មានព្រះអធ្យាស្រ័យដូចលោកមានប្រសាសន៍នោះមែនហើយ, តែក្រែងមានរឿងជាតកនិទានអំពីបុគ្គលណាទុកដាក់កូនចៅដែរឬគ្មានសោះ? ហ្លួងប្រជានុសិដ្ឋសួរ.

បាទ, មានខ្លះដែរ, ឧកញ៉ាធម្មានុសាសក៍ឆ្លើយ– ខ្ញុំបាទឃើញក្នុងសាធុសីលជាតក អដ្ឋកថាទុក្កនិបាត និទានអំពីរឿងព្រាហ្មណ៍ម្នាក់ថា:

កាលព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់គង់វត្តជេតពន, មានព្រាហ្មណ៍ម្នាក់មានកូនក្រមុំ ៤ នាក់ ៗ គ្រានោះ មានប្រុស ៤ នាក់ ម្នាក់រូបល្អ, ម្នាក់ចាស់, ម្នាក់ជាតិខ្ពស់, ម្នាក់មានសីល, មកដណ្តឹងកូនព្រាហ្មណ៍នោះ ៗ ព្រាហ្មណ៍គិតថា " នឹងឲ្យទៅអ្នកណាទើបគាប់ប្រសើរ " ៗ កាលបើគាត់មិនដឹងថាខាងណាស្រួល ក៏ចូលទៅគាល់ព្រះបរមសាស្តា ដំណាលរឿងនុ៎ះក្រាបទូលសួរព្រះអង្គ ៗ

ព្រះសម្មាសម្ពុទ្ធត្រាស់ថា : ម្នាលព្រាហ្មណ៍, កាលពីព្រេងនាយ មានអ្នកប្រាជ្ញឆ្លើយប្រស្នានេះប្រាប់អ្នកដែរ, តែអ្នកកើតទៅ ព្រោះភពបិទបាំង ៗ ព្រាហ្មណ៍សុំអារាធនា ព្រះអង្គក៏ទ្រង់នាំអតីតនិទានមកសំដែងថា :

កន្លងកាលយូរលង់ទៅហើយ, តថាគតជាពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ នៅក្នុងក្រុងពារាណសី, កាលបឋមវ័យបានទៅរៀនសិល្បសាស្ត្រឯនគរតក្កសិលា, លុះត្រឡប់មកស្រុកកំណើតវិញ, បានជាអាចារ្យទិសាបាមោក្ខ (ជាប្រធានក្នុងទិស) មានសិស្សពីស្រុកតូចធំនិគមជនបទផ្សេងៗ មករៀនជាច្រើន ៗ គ្រានោះ អ្នកកើតជាព្រាហ្មណ៍ម្នាក់ មានកូនក្រមុំ ៤ នាក់ ដូចកាលឥឡូវនេះដែរ, មានប្រុស ៤ នាក់មកដណ្តឹងដូចគ្នា ៗ អ្នកមិនដឹងថាឲ្យទៅអ្នកណាស្រួល ក៏ចូលទៅរក

អាចារ្យទិសាបាមោក្ខ, ដំណាលរឿងនោះសព្វគ្រប់ សួរលោកជាគាថាថា:

មនុស្សរូបល្អ, ចាស់, និងខ្ពស់ជាតិ, មនុស្សមានសីលស្អាត ៤ នេះពិត
ខ្ញុំសូមសួរលោកឲ្យពិនិត្យ តើលោកចូលចិត្តមនុស្សយ៉ាងម៉េច?
បើលោកចូលចិត្តមនុស្សបែបណា មេត្តាប្រោសប្រាប់មួយរំពេច
ឲ្យខ្ញុំបានដឹងសព្វសេចក្រេច លោកថាយ៉ាងម៉េចខ្ញុំដើរតាម ។

អាចារ្យទិសាបាមោក្ខឆ្លើយជាគាថាថា:

មនុស្សមានរូបល្អពេកក្លង អ្នកផងស្រឡាញ់ចង់សេពគប់,
មនុស្សមានវ័យចាស់គេគោរព, មនុស្សជាតិខ្ពស់លុបគេកោតក្រែង ។
តែបើខាងខ្ញុំចូលចិត្ត អ្នកមានសីលពិតល្អក្រៃលែង
ព្រោះមនុស្ស ៣ ពួកក្រៅនោះឯង រមែងមានគេតិះដៀលបាន ។
ឯអ្នកមានសីលល្អចំណាប់ កាន់ច្បាប់គ្រហស្ថខ្ពស់ចំណាន
ពុំដែលឲ្យកើតរនះស្នាម អ្នកផងពុំបានរង្កៀសឡើយ ។

ព្រាហ្មណ៍បានស្តាប់អាចារ្យទិសាបាមោក្ខពោលដូច្នោះហើយ, ក៏ផ្សំផ្គុំកូនក្រមុំទាំង ៤ នាក់ឲ្យមានប្តីសុទ្ធតែជាអ្នកមានសីលគ្រប់គ្នា ។

ដែលលោកមានប្រសាសន៍រឿងសាធុសីលជាតកមកនេះ, ខ្ញុំបានស្តាប់បានថា: អាចារ្យទិសាបាមោក្ខជាន់ដើមសរសើរអ្នកមានសីល, ព្រាហ្មណ៍ក៏ឲ្យកូនទៅអ្នកមានសីលតាមនោះ បានសេចក្តីសុខសេចក្តីចំរើន; យើងជាន់ឥឡូវ ក៏គួរឲ្យកូនទៅអ្នកមានសីលដូចព្រាហ្មណ៍នោះដែរ ព្រោះយើងក៏ចង់ឲ្យកូនបានសេចក្តីសុខដូចគ្នា តែលោកមិនទាន់អធិប្បាយឲ្យច្បាស់លាស់ថា "អ្នកមានសីលនោះ ជាមនុស្សមានកិរិយា

ប្រព្រឹត្តដូចម្តេចនោះឡើយ", បើដូច្នេះ សូមអញ្ជើញលោកអធិប្បាយ បន្តិចទៅទៀតមើល ទំពំពេលព្រះសង្ឃឆាន់បង្ហាន់រួច; ដូចម្តេចទៅលោក! ដែលហៅថា មនុស្សមានសីល? ហ្នឹងប្រជានុសិដ្ឋសួរ.

សូមជំរាបលោក ដែលហៅថាមនុស្សមានសីលនោះ បើនិយាយដោយពិស្តារ បានដល់មនុស្សដែលរក្សាសីល៥ កម្មបថ១០ បើនិយាយដោយសង្ខេបក៏គឺមនុស្សដែលមានកាយ វាចា សណ្តាប់ធ្នាប់ត្រឹមត្រូវ មានគំនិតមារយាទល្អ ស្លូតបូត មិនព្រហើនកោងកាច ជាមនុស្សចំរកស៊ីធ្វើការ មិនដើរលេងថ្ងៃថ្ងៃ មិនលេងស្រី មិនផឹកស្រាទឹងមិនលេងល្បែងភ្នាល់ ជាដើម ៗ ឧកញ៉ាធម្មានុសាសក៍ឆ្លើយ.

ខ្ញុំបាទសុំឱកាសលោក, បើលោកបើកឲ្យ ខ្ញុំបាទសុំសួរដេញដោលតទៅទៀត ដើម្បីកំចាយប្រស្នានេះឲ្យទូលាយឡើង ៗ ហ្នឹងប្រជានុសិដ្ឋ តប.

បាទ, មិនអីទេលោក! ខ្ញុំបាទបើកឱកាសជូនបាន តែបានតាមប្រមាណ ដ្បិតខ្ញុំបាទចេះដឹងតិចដែរ, ក្នុងគម្ពីរព្រះពុទ្ធសាសនាមានសំដែងច្រើនណាស់អំពីលក្ខណៈអ្នកមានសីល ខ្ញុំបាទចេះមិនសព្វទេ សុំឆ្លើយជូនលោកតែយ៉ាងសង្ខេបខ្លី ៗ តាមទំនងដែលចេះដឹងខ្លះ ៗ ឧកញ៉ាធម្មានុសាសក៍តប.

បាទ, មិនអីទេ ខ្ញុំក៏ខ្ញុំចុះ ព្រោះពេលយើងក៏ខ្ញុំដែរ, លោកបាំងអី លោក បានជាខ្ញុំបាទឈ្លួចឈ្លីដេញដោលដូច្នេះ ព្រោះធម្មតាមនុស្ស ប្រុសកម្លោះដែលចង់បានកូនក្រមុំរបស់ត្រកូលណា បើដឹងថាត្រកូល នោះគេចូលចិត្តបែបណា ក៏ប្រព្រឹត្តខ្លួនជាមនុស្សបែបនោះដែរ ទ្បែប-ឡបអបដើងគេ ដើម្បីឲ្យគេផ្ទុងគំនិតឲ្យកូនមកខ្លួន, បើមេបារបស់ត្រកូល នោះមិនសង្កេតឲ្យល្អិតល្អទេ ភ្ជាត់គំនិតឲ្យកូនទៅ, ដល់ទៅថ្ងៃមុខ មិនយូរប៉ុន្មាន ក៏ទៅជាអ្នកលេងស្រី ផឹកស្រា លេងល្បែងភ្នាល់ ធ្វើឲ្យកើតទុក្ខវេទនាយ៉ាងខ្លាំងដល់កូនស្រីរបស់ខ្លួន; កាលបើដូច្នោះ ម្ដាយឪពុកតែងបានសេចក្ដីបន្ទោសអំពីកូនស្រីថា "ទាស់តែពីម៉ែឪ បានជាកូនពិបាកដល់ម្ល៉េះ" ម្ដាយឪពុកក៏មិនដឹងបើនឹងធ្វើម៉េច, ព្រោះខ្លួនមិនបានពិនិត្យពិច័យមែន; ហេតុនេះ បើយើងចូលចិត្តឲ្យកូនទៅអ្នកមានសីល យើងត្រូវពិនិត្យឲ្យល្អិតសិនសឹមឲ្យ, រឿងអ្នកមានសីលនេះ តើយើងត្រូវសង្កេតយ៉ាងណាទៅលោក! ទើបដឹងប្រាកដថាជាអ្នកមានសីលមែន ?

ហ្លួងប្រជានុសិដ្ឋស្សូរ .

ឱ! លោក, រឿងសង្កេតរកមនុស្សអ្នកមានសីលនោះពិបាកណាស់ មិនងាយទេ, ឧកញ្ញាធម្មានុសាសក៍ឆ្លើយ - ក្នុងគម្ពីរពុទ្ធសាសនាមានសំដែងថា: បើចង់ដឹងមនុស្សអ្នកមានសីលត្រូវពិសោធដោយការនៅរួមជាមួយគ្នា ឬនៅជិតគ្នាយូរៗ ទើបដឹងបាន, ជួបគ្នាតែមួយភ្លែត ឬគ្រាន់តែ

ព្រួសជី មិនទាន់ប្រាកដទេ, ដូចបទ់ដឹងមនុស្សអ្នកមានប្រាជ្ញា ត្រូវពិ-សោធក្នុងពេលដែលមានគេសាកសួរដេញដោល, ចង់ដឹងមនុស្សអ្នកមានកម្លាំង ត្រូវពិសោធក្នុងពេលដែលមានគ្រោះថ្នាក់, បើមិនទាន់បានពិសោធមើលទេ កុំគាលជឿ, សេចក្ដីនេះយ៉ាងណា; ការជ្រើសរើសរកអ្នកមានសីល ក៏ដូចគ្នា ទំនងជឿប្រញាប់ក្លាមៗ ពេកមិនបានទេ, លុះតែគយឃ្លាំចាំមើលពិតដោយខ្លួនឯង ឬស៊ើបសួរអ្នកផងដែលជាមនុស្សសុចរិត ឬក៏ធ្លាប់ដឹងធ្លាប់ស្គាល់គ្នាជាយូរៗ មកហើយថាជាមនុស្សមានសីលពិតប្រាកដមែនសឹមជឿ; មួយទៀតស៊ើបសួររកពូជពង្សវង្សត្រកូលរបស់អ្នកនោះដោយម៉ឺងម៉ាត់ បើឃើញថា សុទ្ធតែជាមនុស្សរកស៊ីធ្វើការ មានសីលាចារ មានគំនិតមារយាទល្អគប់គ្នា មិនស្រវឹងខូច សឹមជឿយកជាការ ព្រោះធម្មតាមនុស្ស បើពូជពង្សវង្សត្រ-កូលល្អហើយគង់មិនចោលខ្សែពំពីវង្សត្រកូលប៉ុន្មាន; សមដូចសុភា-សិតបុរាណថា "ផ្លែឈើជ្រុះមិនឆ្ងាយពីគល់" ព្រោះហេតុនេះបានជាចាស់ៗពីបុរាណតែងពោលថា "ធ្វើស្រែឲ្យមើលស្មៅ ទុកដាក់កូនចៅមើលផៅសន្តានគឺមើលពូជ" នោះឯង. បើមិនទាន់បានពិសោធចាំងសាម៉ីខ្លួន ឲ្យដឹងពូជពង្សទេ កុំគាលទុកចិត្តឲ្យសោះ ព្រោះមនុស្សយើងមានពុតត្បុតច្រើនបែបច្រើនយ៉ាងណាស់ ខ្លួនកាលបានរៀនសូត្រធម៌អាថ៌ពេះដឹងច្រើន បានឈ្មោះថាជាអាចារ្យហើយ ក៏គង់តែជាមនុស្ស

ឥតសីលទៅបាន, បើយើងបានពិនិត្យទាំងសាមីខ្លួន ទាំងពូជពង្សវង្សត្រកូលឃើញថា ជាអ្នកមានសីលាចារកិរិយាមារយាទល្អត្រឹមត្រូវហើយសមឲ្យ, បើនៅតែមិនស្រួល នោះយើងក៏លួមអស់ចិត្តដែរ កូនស្រីយើងក៏រាប់ទោសយើងពុំបាន ធ្វើម៉េចជាកម្មរបស់យើងនឹងកម្មរបស់វា, យើងតោងគិតដល់កម្មនឹងផលរបស់កម្មផង ទើបស្រាលចិត្ត ។

ណ្ហើយលោក! យើងលួមបញ្ចប់ប្រស្នាប៉ុណ្ណឹងចុះ, បើលោកមិនអស់ចិត្ត ចាំថ្ងៃក្រោយ បើមានពេលសមយើងប្រឹក្សាគ្នាម្ដងទៀត ឬលោកអញ្ជើញទៅប្រឹក្សានឹងលោកអ្នកប្រាជ្ញផងបណ្ឌិតណាទៀតក៏បាន, ពេលនេះលួមសង្ខេបប៉ុណ្ណឹងហើយ ។

សាធុ! សាធុ! ល្អហើយ! ល្អហើយ! លោក, ខ្ញុំបាទអស់ចិត្តហើយរឿងរកកូនប្រសាប្រុសនេះ, នៅតែរឿងរកកូនប្រសាស្រី មិនទាន់បានដឹងសោះ, ខ្ញុំបាទចង់សួរលោកតទៅទៀត តើបានឬទេ ? ហ្នឹងប្រជានុសិដ្ឋទទួលអំណរដោយសេចក្ដីរីករាយ !

ណ្ហើយលោក! កុំអាលសួរ, ចាំក្រោយបើមានឱកាសសមយើងប្រឹក្សាគ្នាទៀត; ពេលនេះ លួមប៉ុណ្ណឹងចុះ ព្រោះដល់ពេលបាយហើយ; មិនអីទេលោក! បើប្រស្នាក្រោយនោះឆ្ងាយៗ លួមទឹងប្រាជ្ញខ្ញុំបាទខ្ញុំបាទឆ្លើយជូនបានទៀត កុំព្រួយ!! ទីកញ្ញាធម្មានុសាសន៍ គប.

កាលអស់លោកត្រៃមន្ត្រីឃុនពេហារកោសល, ហ្លួងប្រជានុសិដ្ឋ នឹងឧកញ៉ាធម្មានុសាសក៍ ប្រឹក្សាធម៌អាថ៌ក្បួនច្បាប់ ព្រមព្រៀងគ្នាហើយ ដល់វេលាព្រះសង្ឃឆាន់រួចល្មម, ឧកញ៉ាឧត្តមសម្បត្តិ ក៏ចាត់ចែងអាហារដ៏ផ្ចិតផ្ចង់ ជូនអស់លោកត្រៃមន្ត្រី ព្រមទាំងឧបាសកឧបាសិកា ពិសាឆ្អែតស្កប់ស្កល់គ្រប់គ្រាន់, លុះអស់លោកត្រៃមន្ត្រីនឹងឧបាសកឧបាសិកាទាំងនោះ ពិសាភោជនាហាររួចហើយ ក៏ជូនពរសព្វសាធុការដល់ឧកញ៉ាឧត្តមសម្បត្តិព្រមទាំងគ្រួសារ ហើយលាចេញទៅនេហដ្ឋានរៀងខ្លួន ។

# កំពូលកំសត់

## លោកហាក់-ឈៀង តែងនិងរៀបរៀង

(តមក)

"បាទ ការត្រង់ណេះខ្ញុំបាទហ៊ានសន្យាជូន បើកាលណាហើយខ្ញុំបាទប្រព្រឹត្តបទល្មើសឯណាមួយលើនាង សូមឲ្យលោកផ្ដន្ទាទោសរបស់ខ្ញុំបាទជាឧក្រិដ្ឋចុះ គឺខ្ញុំបាទសុខចិត្តចុះចេញតែខ្លួនទទេ ប្រគល់ទ្រព្យសម្បត្តិផ្ទះសម្បែងជូននាងទាំងអស់ ត្រង់ណេះគួរលោកៈជឿចុះ ខ្ញុំបាទមិនដែលពោលពាក្យមុសាវាទទេ ដូចលោកបានប្រសព្វនឹងខ្ញុំ បានស្គាល់គំនិតមារយាទស្រាប់ហើយ" ។

"លោក! មិនបាច់លោកសន្យាក៏ខ្ញុំជឿចិត្តលោកដែរ បានជាខ្ញុំតឹងតែងបន្តិចនោះ គឺពីព្រោះអាណិតដល់នាងប៉ុណ្ណោះទេតើ តែការនេះខ្ញុំមិនហ៊ានសម្រេចដោយខ្លួនខ្ញុំដែរ ចាំខ្ញុំសួរចិត្តក្មួយខ្ញុំមើល បើនាងព្រមនោះក៏ប្រសើរហើយ បើនាងមិនព្រមខ្ញុំក៏មិនដឹងធ្វើដូចម្ដេចដែរ" ។

យប់មួយជាឱកាសល្អ វត្ថនារីមានមុខស្រស់បស់ មារបស់នាងក៏និយាយជាមួយនឹងនាងថា "ម៉េចចៅក្មួយ! ក្មួយបានដំណឹងពីសុភិន្ទ្រដែរឬអ្វី?

"ចា៎ះទេ! គ្មានបានដំណឹងអ្វីបន្តិចបន្តួចមកសោះ ខ្ញុំហៅឆ្ងល់អស់យ៉ាងហើយ" ។

"ចុះសោកិតនៅតែកាចឬអ្វី? ឯប្រពន្ធថ្មីរបស់គេ នៅតែស្រស់ស្រលឬដូចម្ដេច ?

"មើលទៅប្រហែលជានៅដដែលហើយលោកគ្រូ" ។

"ចុះឯងលែងទាក់សោកិតទៀតហើយឬយ៉ាងដូចម្ដេច ?

"បាទ លែងទាក់ហើយតាមប្រសាសន៍លោកគ្រូ ជាតិនេះខ្ញុំបានជាជ្រុលហួសទៅហើយ ជាតិក្រោយៗ ខ្ញុំលែងជួបនឹងគាត់ទៀតហើយ ចំណែកស្រុកខ្មែរខ្ញុំមិនឲ្យទៅតាមពោះនឹងអ្នកដទៃទេ" ។

មាស់នាងដកដង្ហើមធំមួយសន្ទុះ ទើបនិយាយឡើងថា "ណ្ហើយក្មួយ! ក្មួយឯងកុំព្រួយពេកនាំតែស្គមទេ បើក្មួយស្រឡាញ់កូននោះ តោងក្មួយរកវិធីឯណាមួយជួយឲ្យមានកន្សៀងកំហែង កុំឲ្យកូនវាកើតទុក្ខ ដល់បានជួបមុខគ្នា ក្មួយកុំស្មានថាមិនបានជួបគ្នាថ្ងៃណាមួយនោះ ព្រោះផែនដីវិលចុះវិលឡើងគង់តែប្រទះគ្នាទេ" ។

"ខ្ញុំក៏គិតឃើញដូច្នោះដែរ តែមិនដឹងគិតដូចម្ដេច" ។

"បើដូច្នោះក្មួយតាមមាទេ បើមារកសេចក្ដីសុខឲ្យក្មួយបាន ?

"ចុះលោកគ្រូឲ្យក្មួយតាមបទណា មានប្រសាសន៍មកចុះក្មួយនឹងធ្វើតាម បើក្មួយអាចនឹងធ្វើតាមបាន" ។

"ក្មួយស្គាល់លោកចៅក្រមសាលាដំបូងទេ? -ស្គាល់- លោកនោះមានគំនិតខាងយោងល្អណាស់ ហើយមានសម្បត្តិក៏ក្រាស់ក្រែល លោក

ពេញចិត្តនឹងឯងណាស់ ហើយសន្យានឹងនាងថានឹងឲ្យឯងបានសេចក្ដីសុខ តែឯងយល់ដូចម្ដេច ?

នាងក៏ឆ្លើយតែក្អកពឹងថា . . . ពានហ្វាងសាលាដំបូងមានសម្បត្តិស្ដុកស្ដម្ភ អាចឲ្យសេចក្ដីសុខដល់នាង ចំពោះនាងដែលព្រាត់ប្រាសចាកកូនសម្លាញ់. . . ។

"ម៉េចក្មួយ ក្មួយយល់ព្រមឬ?

នាងក៏បើកភ្នែកឡើង មានទឹកភ្នែកហូរហៀរជោកថ្ពាល់ទាំងគូ ហើយនាងខ្សឹកខ្សួលមួយសន្ទុះ បាននិយាយឡើងថា "ទេ! ទេ! លោកពូ. . . កុំមានប្រសាសន៍អំពីរឿងនេះទៀត ព្រោះចិត្តខ្ញុំជាចិត្តម្ដាយដែលស្រឡាញ់កូន មិនត្រូវគិតអ្នកដទៃក្រៅអំពីកូនឡើយ ឱ! សុភ័ន្ទមាសម្ដាយអើយ . . .!! ។

បទទី ១០

## បារីស្មោះត្រង់នឹងចៅហ្វាយឆាយ

មានល្ងាចមួយ ភ្នែនារីព្រាងនឹងជិះស៊ីក្លូយកខ្យល់អាកាស ទើបនាងផ្លាស់សំលៀកបំពាក់ហើយក៏ចុះចេញពីផ្ទះដើរទៅក្រៅ ចួនជាស៊ីក្លូមួយមកដល់ នាងក៏ឡើងជិះឲ្យគេបរតាមផ្លូវ "កេក្ដិនរេក្ដម" ។

ឯក្រែយនាយខាងណោះ ជួយចង្វាទៅស្ទួនរៃទៅឆ្ងាយ មានសេចក្ដីនឹកត្រេបដណ្ដប់ដុំផិតដោយអនេរ៉ា មានកើងអត្ថិសនិភ្ជាព្រោង

ព្រាតបាំងនៅក្នុងទឹក ជាសណ្ឋានសសរភ្លើងវែងៗតាមក្រសែទឹក ដែលហូរសន្សឹមធ្លាក់ចុះទៅទន្លេធំ ៗ ខាងលើពពកសក្បុះភ្នំចិញ្ចាច រូបមានពពកខ្មៅ បាំងព្រះចន្ទ្រើបនឹងរះជិតនៅតែមួយចំហៀង ក្រឡេកមើលទៅឃើញក្រាងៗ តែអាចចុះទៅក្នុងទន្លេឲ្យជាលប្រាត់បាន ៗ កណ្ដាលផ្ទៃមេឃ មានផ្កាយភ្លឺផ្លេកផ្លូចជាត្បូងពេជ្រ គឺផ្កាយយាមនង្គ័ល ដែលធៀងជិតផ្កាយសេះនឹងផ្កាយកូនមាន់ មានពន្លឺប្រឡ្បះគួរឲ្យគន់ គួរឲ្យចង់ចាប់លេង គួរឲ្យស្នេហាក្រៃកក្រៃអាល ៗ

ឯព្រៃខាងអាយភ្លឺចាំងដោយគោមធេះឯង នៅត្រង់កំពង់ធំស្រឡះអណ្ដែតលើប៉ោតដែកធំៗ ជាច្រើន ហើយមានស្ពានដែកកាត់ទាំងបីជ្រុងទ្រឲ្យទឹងមិនឲ្យឃ្លេងឃ្លោង មានកប៉ាល់មួយធំចង្ក្រានស្វាត់ឈឹង ពីរបំពង់ភ្លើងផ្សែងខៀវហុយរុយៗឡើងទៅលើខាងណោះ ទូកនាក់ជាច្រើនបោះយុថ្កាចតនៅទីងឥតកំរើក ពេលនោះស្ងាត់ជ្រៀបឥតឮសូរអ្វីក្រៅអំពីសត្វលោក ដែលបោកលើប្រាំងលាន់គ្រៀកៗ ពីរោះជល់ត្រចៀកពន់ពេក គួរឲ្យនឹកសង្វេគងាកក្រឹកាលនោះណាស់ យូរៗមានទូកតូចមួយលយកាត់ទឹកទៅបាត់ក្នុងសេចក្ដីងងឹតទៅ ឮសូរតែចង្វាក់ចែវដែលកាយទឹកព្រមៗគ្នា ស្រាប់តែបន្តិចលេចចេញពីកណ្ដាលទន្លេនូវសព្ទចំរៀងយួនដងត្រីពិរោះលន្លោចល្ហេងល្ហើយ មានបទសមនឹងយប់នៃក្នុងនោះឯង ៗ

ឯអាកាស សេចក្ដីសៅសោក សេចក្ដីសម័យក្ដើតក្ដើន សេចក្ដីស្ងាត់កំបាំងលាយឡំគ្នានឹងលំអរបស់ធម្មជាតិ ហាក់ដូចជាប្រហាក់ប្រហែលឃើញមិនច្បាស់និយាយមិនកើត ដែលសមដល់ទឹកចិត្តរបស់រ័ត្ននារីនាវេលាគ្រានោះ ។

នាងក៏បានសៀយទុក្ខបណ្ដោយឲ្យអានុភាពគ្រែកាលនោះ គ្រប់គ្រងកាយនិងវិញ្ញាណរបស់នាង ហើយនាងផ្អែកខ្លួនទៅនឹងពូកស៊ីក្លូដេចក្អែកព្រឹមៗ ព្រោះនាងមានសេចក្ដីទំនុកទុកចិត្តដល់ជោគវាសនាឡើងវិញហើយ នាងភ្លេចគិតថានាងនៅលើស៊ីក្លូ ចង់អ្នកធាក់បរទៅដល់ទីណា នាងក៏មិនដឹង ស្រាប់តែពួកអ្នកស៊ីក្លូនោះស្រែកប្រាប់នាងឡើងថា "អ្នក ដល់ផ្ទះហើយ ល្មមអញ្ជើញទៅសម្រាន្តចុះយប់កាន់តែត្រជាក់ ហើយក្រែងវែរជាមិនស្រួល" ។

នាងក៏ភ្ញាក់ព្រើតដើរចុះចេញពីស៊ីក្លូ ទើបឆ្ងល់ណាស់ ចុះអ្នកហ្នឹងមកពីណាមក បានជាយកចិត្តទុកដាក់ដល់រូបនាង នាងអត់ទ្រាំមិនបាន ក៏សួរឡើងថា "នែអ្នកស៊ីក្លូ អ្នកឯងនៅទីតំបន់ណា បានជាចិត្តល្អដល់ខ្ញុំម្ល៉េះ? ហា! យកថ្លៃឈ្នួលទៅ" ។

អ្នកនោះទទួលយកហើយ ក៏សើចបន្តិចៗ ថា "អ្នកមិនស្គាល់ខ្ញុំបាទទេឬ?

"ចា៎ះទេ" ។

"អ្នកភ្លេចហើយ ចៅប្រុសរបស់អ្នកដែលតែងជូនសុកខ្ញុំទៅរៀនអក្សររៀងរាល់ថ្ងៃ ខានតែថ្ងៃព្រហស្បតិ៍និងអាទិត្យប៉ុណ្ណោះ" ។

"ឱ! ចាំខ្ញុំនឹកមើលសិន តាព្រំ! តាព្រំ! មែនហើយ ចុះតានៅឯណាសព្វថ្ងៃ ដូចម្តេចក៏ឃ្លាតមកដល់ស្រុកនេះ មកយូរហើយឬអី?

"បាទបាន! ខ្ញុំបាទតាំងពីមានហេតុមក ខ្ញុំបាទក៏វិលទៅផ្ទះវិញ តែគេរកការខ្ញុំបាទគ្មាន បានជាស៊ូកាត់ស្រុកមករកទទួលទានជាអ្នកដាក់ស៊ុកក៏មួយថ្ងៃខ្ញុំបាទរកបានបួនប្រាំរៀលដែរ គ្រាន់នឹងចំអែតពោះ ហើយនឹងទុកសន្សំខ្លះ តែយ៉ាប់ណាស់ការនេះ ត្រូវតែរត់ទាំងថ្ងៃត្រង់ ចេញញើសជាប់ខ្លួន ខំទទាល់ហើយបានជាបេះតែទ្រាំទៅ នាំឲ្យខ្ញុំនឹកដល់ព្រះគុណម្ចាស់ថ្លៃ ដល់ត្រង់ណេះ តាព្រំក៏លើកដៃបួងសួងឡើង "កាលខ្ញុំបាទនៅជាមួយនឹងអ្នកនោះ ខ្ញុំបាទបានសេចក្តីសុខគ្រប់ប្រការ ហើយទុកជាខ្ញុំបាទឃ្លាតមកឆ្ងាយក៏ខ្ញុំបាទនៅតែស៊ើបសួរ អំពីចៅហ្វាយ បានដឹងសព្វគ្រប់" រួចតាព្រំក៏ដកដង្ហើមធំជាទុក្ខ ។

ចំណែកស្ត្រីកាលបើស្គាល់ច្បាស់ជាបាវចាស់របស់នាងហើយ នាងក៏មានសេចក្តីត្រេកអរពេក ចមា អង្វរតាព្រំឲ្យលែងដាក់ស៊ុកឲ្យមកនៅនឹងនាងដូចដើមវិញ តាព្រំក៏ព្រមតាម តាំងពីថ្ងៃនោះមក នាងតែង

ហៅតាព្រឹមកនិយាយតែពីរឿងសុភទ្រ ដែលនាំឲ្យនាងបានសប្បាយរីករាយចិត្ត ។

ថ្ងៃមួយរត្ននារីហៅតាព្រំចូលមកហើយនិយាយថា "តា ខ្ញុំទុកចិត្តតាណាស់ ដោយហេតុនេះខ្ញុំនឹងប្រគល់សំបុត្រមួយច្បាប់នេះហើយនឹងកញ្ចប់នេះមួយ ក្នុងកញ្ចប់នេះមានប្រាក់ចំនួន ១០០រ.០០ ហើយនឹងប្រាក់ ២០រ.០០ ទៀតជាសោហ៊ុយតាជិះឡាន តាតាណាំតនាំរបស់ទាំងនេះយកទៅឲ្យកូនរបស់ខ្ញុំផង តាយកតែបុណ្យប៉ុណ្ណោះណាតាណា តែតាប្រយ័ត្នកុំឲ្យអាពុកកាប់ជឹង ក្រែងខូចការទៅ" ។

កុំព្រួយអីអ្នក បើជីវិតខ្ញុំនៅរស់ត្រឹមណា ខ្ញុំជានាំនឹងយករបស់នេះឲ្យដល់កូនរបស់អ្នកឲ្យទាល់តែបាន ទុកជាចង្អៀតចង្អល់ដូចម្ដេចក៏ខ្ញុំបាទសុំប្ដូរជីវិតត្រឹមណោះដែរ ព្រោះអ្នកមានគុណនឹងខ្ញុំច្រើនណាស់ ។ មួយវិញទៀត ខ្ញុំបាទក៏ស្រឡាញ់សុភទ្រច្រើនណាស់ដែរ ព្រោះខ្ញុំបានបីបតាំងពីតូចក្របធ្មារមក ហើយបាននាំទៅសាលារៀនផង ។

រួចតាព្រំក៏លារត្ននារី រៀបចំប្រដាប់របស់ខ្លួនវេចដាក់ក្នុងក្រមាយួរចុះទៅជិះឡាន លុះដល់កំពង់ធំកាលណា តាព្រំក៏ចុះកណ្ដាលផ្លូវបង្ការកុំឲ្យសោកិតដឹង ហើយដើរចូលទៅលេងផ្ទះសម្លាញ់ "យើ! អ្នក-កំឡោះបាត់មុខមាត់យូរណាស់ហើយមិនឃើញ អញស្មានថាទៅជាផ្អ សឹងហើយតើ ម៉េចអាសម្លាញ់ឯងសប្បាយជាទេឬ?

"អើអា! អញសប្បាយណាស់ អញនៅឯភ្នំពេញឯណោះ សព្វថ្ងៃជាក់ស៊ីក្លូបានកំរៃគ្រាន់សមដែរ ចុះអាសំឡាញ់ឯងនៅប្រមឹកស្រាឬអា? ក្បាលចាស់ហើយម្តេចក៏មិនគិតកែក្បាលសិល ឬឯងមិនឃើញថាខ្លួននៅជាកំឡោះនៅឡើយ" ។

"ទេអា! អញឈប់ផឹកឈប់ស៊ីហើយ ឥឡូវអញចូលវត្តអាពមហើយ ចុះអាមានការធុរៈអ្វីបានជាមក?

"អញរលឹកអាសំឡាញ់ឯងបានជាមក ម៉េចអាមិនរលឹកអញទេឬអ្វី?

"ម៉េចឯងនិយាយយ៉ាងហ្នឹង?

ជាហើយសំឡាញ់ក៏ស្ទុះមកឱបតាព្រំហើយអង្អែលក្បាលលេង តាព្រំក៏សាកសួរដំណើរអំពីសុខទុក្ខ តែមិនបានប្រាប់សំឡាញ់អំពីកិច្ចដែលត្រូវបំពេញ ជាប់និយាយជាមួយនឹងសំឡាញ់នោះទាល់តែយប់ជ្រៅ បានតាព្រំលាសំឡាញ់ "ណ្ហើយអា! យើងនិយាយគ្នាប៉ុណ្ណឹងចុះ យប់ជ្រៅណាស់ហើយ ក្រែងអ្នកជិតខាងគេធ្ងន់គេ អញលាសិនហើយ ចាំថ្ងៃក្រោយយើងជួបគ្នាទៀត" ។

"ម៉េចអីចឹងអាសំឡាញ់ មកដល់ផ្ទះអញហើយក៏ទៅឯណាទៀត នៅដេកនឹងគ្នាមួយយប់ហើយគ្នារលឹកណាស់" ។

"ទេអា! អញមានការប្រញាប់ណាស់នៅមិនបានទេ" ។

"ចុះឯងមានផ្ទះសម្បែងឯណាក៏ទៅតាំងយប់ កុំធ្វើជាប្រេះរឿយ អីក៏ដូម្ល៉េះ អញមិនឲ្យឯងទៅទេ" ។

តាព្រំនឹកអាណិតចង់នៅជាមួយនោះ តែនឹកដល់កិច្ចរបស់ខ្លួនក៏កាត់ចិត្តលាសំឡាញ់ តែសំឡាញ់នោះនៅតែទទូចឲ្យនៅ "ឯងមិនព្រមក៏រាហ៊ានទៅចុះ តែយប់ងងឹតនៃក្រងមានគ្រោះថ្នាក់ ស្រុកឥឡូវមិនល្អដើរយប់ត្រៅតែឯងទេ" ។

តាព្រំអង្វរថា "ណ្ហើយអាសំឡាញ់ ឯងកុំព្រួយទឹងអញអីគ្នាមានកិច្ចធំណាស់ ហើយកិច្ចនោះមិនឲ្យអ្នកណាដឹងមួយជាពីរផង ឯងកុំខឹងអី ស្អែកអញមកវិញទេ" ។

រួចតាព្រំក៏ដើរកាត់សេចក្តីងងឹតតាំងកណ្តាលយប់ទៅ ព្រោះដឹងថាពេលព្រឹកពីព្រលឹមសុភិន្ទ្រនៃងក្រោកជាបបរ ហើយនៅពេលនោះគ្មាននរណាក្មាក់ ដាទុកាសល្អគួរប្រគល់របស់រ័ត្នទាវឲ្យសុភិន្ទ្រ នៅប្រហែល ១០០ ម៉ែត្រប៉ុណ្ណោះ បានដល់ផ្ទះសោភិតហើយ តាព្រំក៏ខំដើរឲ្យលឿន! ។

ស្រាប់តែឮសូរមនុស្សប្រែននាក់តែពីមុខមក តាព្រំក៏ឧបក្រមាជាប់ រួចក៏ឃើញមនុស្សប្អូនទាក់ស្មៀកខោពាក់ខៅ ចូលជិតហើយពោមពោមតាព្រំ រួចម្នាក់ក៏ហៃងសួរឡើងថា "នៃតាគំៗ ឯងទៅណាមកណាមានលុយកាក់ទេ ?

# ប្រជុំសុភាសិតខ្មែរតាមលំដាប់អក្សរ

## ហង្សនិពន្ធមន្ត្រី ញ៉ុក-ថែម

រួបរួម

### អក្សរ ប (តទៅ)

៙ បាយត្រជាក់ឲ្យតែសម្លក្តៅ ស្រីទៅៗ ចុះឲ្យតែនៅក្មេង ។

៙ បើកាចៗ ឲ្យគេគោត បើឆោតៗ ឲ្យគេអាណិត ។

៙ បើចង់ចំណេញកុំខ្លាចខាត បើចង់ស្អាតកុំខ្លាចយូរ ។

៙ បើមិនជួយចូក ជួយថែវ, កុំយកជើងកទឹក ។

៙ បើឮសូរផ្គរ, កុំអាលចាក់ទឹកបំពង់ចោល ។

៙ បើលួចគេរត់គ្រាន់, ប្រយ័ត្នតែគេទាន់កាត់ក្រែល ។

៙ បើស៊ីត្រង់ណា កុំជុះត្រង់នោះ ។

៙ បើស៊ីកុំតាមឃ្លាន គិតប្រមាណអស់គ្នា ។

៙ បើទឹករស់ៗ ឲ្យគាប់ បើទឹកល្អាប់ៗ ឲ្យគួរ ។

៙ បើអាក្រក់ៗ ចុះឲ្យតែល្អ បើក្រៗ ចុះឲ្យតែមាន ។

៙ បែកមិត្រ កុំឲ្យយកជាមិត្រ ។

៙ បំណាច់ទឹងបេះៗ គោរឲ្យគេគោត, បំណាច់ទឹងឆោតៗ ឲ្យគេ អាណិត ។

១ បំណាច់នឹងបាប តោនឲ្យផ្លាបមាត់ ។

១ បំណាច់នឹងខូច ។ ឲ្យបាទការ, បំណាច់គេថាតោនឲ្យស៊េម មាត់ ។

១ ប្រពន្ធពីរ គោបី ដំរីមួយ នាំឲ្យព្រួយចិត្ត ។

១ ប្រពន្ធល្អច្រើនចាញ់ប្ដី ពាក្យច្រើនកូនចាញ់អាត្មា ។

១ ប្រមាត់ដូចនឹងឡើងទ្រើង ។

១ ប្រហែលរាំបាត ប្រយ័ត្នរាំគង ។

១ ប្រាក់កំបង ចងកំដាប ឬ ប្រាក់កែបង ចងកែដាប គូថ កែកាប កូនកែកើត ។

១ ប្រាជ្ញពុំស្មើពុក, ប្រើលំអុតពុំស្មើគាប់, មានគុណពុំស្មើមានកញ្ញ ។

១ ប្រាជ្ញមិនស្មើប្រែប បរើស្មុកត្រចៀកខូច មិនស្មើអាឡេមឡើម ។

១ ប្រាជ្ញចុះរណ្ដៅ ខ្លៅឡើងសួគ៌ ។

១ ប្រាជ្ញអានប្រាជ្ញា, រមាសអានបន្ទា, ខ្លាអានព្រៃ, ដំរីអានរនាម, ត្រីអានទឹក, ទាហានអានសឹក, ប្រមឹកអានពែន ។

១ ប្រាសពីជនវៃក, ទៅផ្អែកលើពូក ស៊ីសម្លាប់ជ្រូក បាយសុខអង្ករដើម ។

១ បើត្រាប់សត្វក្អែក, កុំបីត្រាប់ពុតទន្សាយ ។

១ បើត្រាប់កុកសាប់, កុំបីត្រាប់កុកស ។

១ បើត្រាប់ឫស្សី, កុំបីត្រាប់ស្លាយកន្ទ្រាញ ។

១ បើត្រាប់អ្នកប្រាជ្ញប្រាយ, កុំបីត្រាប់ខ្លៅសាមាន្យ ។

១ បើទៅជាត្បូងចញ្ចៀន, ក្រវេចក្រវៀនជាមៀនកាំបិត ។

## អក្សរ ផ

១ ផឹកស្រាក្លាសំដី ។

១ ផ្ទុករទេះតាមចំណុះ ។

១ ផ្លូវវៀចកុំបាបង់, ផ្លូវណាត្រង់កុំដើរហោង, ដើរដោយស្នាមគន្លង, ជម្រាយអ្នកចាស់បុរាណ ។

១ ផ្លែត្រឡាចគង់មានបណ្ដូល, មនុស្សពាំងមូលគង់មានចិត្ត ។

១ ផ្លែឈើចាញ់សន្ទុក ត្រីច្រើនទឹកល្អក់ពុំជា ទ្រព្យច្រើនព្រួយរក្សា ទ្រព្យតិចណាព្រួយរិះគិត ។

## អក្សរ ព

១ ពងមាន់កុំជល់នឹងថ្ម, ប៉ុពងមាន់សោត, កុំប្រះឡាតជល់នឹងថ្ម ។

១ ពងមាន់ក្នុងសំបុកលោតទៅទាំងក្អក, កន្ទួបអាចម៍គោលោតទៅទាំងពស់វែក, ត្រីក្នុងសរផ្ដែកគ្រវែងទាំងឆ្នា ។

១ ពាក្យខុសកុំឲ្យស្តាប់, សេចក្តីគាប់ឲ្យរំពឹងគិត ។

១ ពាក្យក្រកុំអាលប្រាប់, ពាក្យឥតសព្ទកុំអាលថ្លែង ។

១ ពាក្យគ្រវែងវែង, ពាក្យពិតវែងស្ទែង ។

១ ពាក្យពិតកុំឲ្យវែង, ពាក្យពិតស្ទែងពុំគួរលាក់ ។

១ ពាក្យពេញលោកស្រដី, ជាកុំបីចិញ្ចឹមខ្លា ។

១ ពាក្យស្មែងកុំស្អប់, ពាក្យគាប់ឲ្យយក ។

១ ពាក្យម្តាយ, ទំនាយគ្រូ ។

១ ពិសាក្រណាទឹងឃ្លាន, អាក្រក់ប៉ុន្មានក៏ក្រណាទឹងស្រឡាញ់ ។

១ ពុតគ្រូកុំគ្រាប់, ច្បាប់គ្រូឲ្យយក ។

១ ពូជគោជ្រៃលែង, ពូជស្រីផ្តែរែង, ពូជសិស្សគ្រូបី, ពូជខ្មែរបង់ម្ចាស់ ។

១ ពូនកែមុខទុកគូថនៅកណ្តាលវាល ។

១ ពេទ្យគោល្ងង់, មេមត់ស្លាប់កូន, សុភាពញាក់ក្តី, ផ្កាពេទ្យគោល្ងង់, មេមត់ស្លាប់កូន សុភាពញាក់ក្តី, ក្រពើលង់ទឹក, ម្រឹគដាច់ព្រៃ ។

១ ពោះជាទេវតា, មាត់ជាទេវតា ។

១ ព្រះមិនសម, ព្រហ្មមិនជួយ ។

១ ពោះគោ, ពោះក្របី ។

## អក្សរ ភ

៙ ភូតនៅហោរ, ហោរទៅជាឧទង ។

៙ ភ្លើងឆេះមកតែពិស្រោន ។

៙ ភ្លេភ្លើ ដូចក្រពើរង្វេងបឹង ។

## អក្សរ ម

៙ មនុស្សកុំមើលងាយមនុស្ស ។

៙ មនុស្សទើងកុំឲ្យលាងចាន, មនុស្សឃ្លានកុំឲ្យដាំបាយ ។

៙ មនុស្សខ្លាំងទុកជារបង, មនុស្សកាចទុកជាខ្នង, មនុស្សកោងទុកជាសម្រាស់, មនុស្សស្លូតទុកជានាំង ។

៙ មនុស្សឆ្លាតគេថាដោភ, មនុស្សស្លូតគេថាល្ងង់, បេះគេថាកាច, ប្រាជ្ញគេថាព្រោល ។

៙ មនុស្សពាលរែងផ្ដេផ្ដាស់, ក្រយស់រែងអួតធន, ខ្លាចរែងធ្វើហ៊ាន, គ្មានប្រាជ្ញារែងអួតចេះ ។

៙ មនុស្សទើងប្រាក់, យក្សទើងសាប ។

៙ មាត់មានគ្រប, ដបមានឆ្នុក ។

៙ មាត់តែប្រកែក, អរម្រែកតែទទួល ។

៙ មាត់ពិរោះ ពោះកាតក ។

(មានត)

# ច្បាប់ក្រមបរិយាយ

## លោកញ៉ុក-ធូ គ្រូបង្រៀនជំនួយ

### នៅវិទ្យាល័យស៊ីសុវត្ថិ

(តមក)

ត្រង់លោកទូន្មានថា "ចិត្តនោះឲ្យហ៊ាន បំពេញព្រះផ្នួស" ហេតុដូចម្តេចក៏ចាំបាច់ថា "ហ៊ាន" ទើបបានបួសបាន? ថាធម្មជាតិមនុស្សបុថុជ្ជននេះ រមែងប្រកបដោយកិលេស គឺសេចក្តីសៅហ្មងនៅក្នុងចិត្ត ជាមនុស្សពាលអាក្រក់ ងងឹតពុំយល់ផ្លូវសុខនិងទុក្ខ ៗ កាលខ្លួននៅក្នុងវង្វេងទៅដោយសេចក្តីសប្បាយច្រើនប្រការ ប្រាថ្នានូវកាមគុណជាអារម្មណ៍ ម្ល៉ោះហើយនឹងដកខ្លួន ឲ្យរួចរបូតអំពីអន្លង់នេះបានដោយក្រ ព្រោះសេចក្តីជំពាក់ក្នុងកាមនេះមកគ្របសង្កត់ មានទម្ងន់ជន់ពន់ប្រមាណណាស់ ៗ ខ្លះជាប់ជំពាក់នឹងសម្បត្តិទ្រព្យ បុត្រភរិយា ខ្លះជំពាក់ក្នុងសប្បាយនឹងបុណ្យស័ក្តិ, ខ្លះខ្លាចថានឹងទ្រទ្រង់ធម៌វិន័យពុំបាន ព្រោះឃើញថា តែចូលទៅបួស ត្រូវឲ្យក្លាហានលះបង់នូវអំពើកាមរាគឲ្យជ្រះស្រឡះអស់អំពីចិត្ត, នេះឃើញជាក្រៃណាស់ នឹងលះមិនបានទេ ក៏ក្រាញចិត្តមិនហ៊ានបួស អត់ធន់ដេកត្រាក្នុងលាមកទៅវិញទៅក៏មាន ៗ

១ ទៀត បើអ្នកណាបានបួសជាបព្វជិតហើយ ត្រូវកាន់ក្រិត្យតាមវិន័យ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងទុកមកថា ភិក្ខុសាមណេរ

គប្បីធ្វើខ្លួនឲ្យបរិសុទ្ធល្អ កុំឲ្យខុសធម៌ ខុសវិន័យ, ឲ្យលះបង់អំពើទុច្ចរិតលាមកឲ្យអស់ចេញ កុំឲ្យមានសេសសល់ជាមន្ទិលដល់តិចឡើយ គឺលះ លោភៈ ទោសៈ មោហៈ នេះឯងជាដើម ។

ដ្បិតជនានុជន នៅទាលោកិយនេះ គឺមានច្រើនមកហើយដែលជាមនុស្សអន្ធពាល ពុំសូវមានគំនិតគិតកែប្រែមារយាទឲ្យល្អឡើងវិញបាន ដូចអ្នកលេងល្បែង ជក់អាភៀនផឹកស្រានិងល្បែងភ្នាល់ជាដើម នោះកម្រមានអ្នកលះបង់បានដោយងាយឡើយ, ខ្លះលេងទាល់តែចាស់ជក ទាល់តែក្រអស់ធនធានក៏មិនឈប់ ។

ឯពួកអ្នកមានទ្រព្យ និងបុណ្យស័ក្តិ បើមានសទ្ធាសេចក្តីជ្រះថ្លាបានត្រឹមបរិច្ចាគទ្រព្យរបស់ធ្វើទានប៉ុណ្ណោះ តែនឹងលះយកភេសទៅបួសពុំបានឡើយ ។

ដូច្នេះ ការលះកាមគុណនិងសម្បត្តិទ្រព្យនិងបុណ្យស័ក្តិ ហើយចូលទៅបួស ប្រតិបត្តិធម៌វិន័យ ជាការក្របំផុត, ដែលគេបាន ក៏បានដោយពិបាក ។

ប៉ុណ្ណោះល្មមយល់បានថា អ្នកបួសសុទ្ធសឹងតែជាបុគ្គលលះយកភេសបានដោយក្លាហាន ហើយញុំាងចិត្តឲ្យមូលចូលទៅកាន់ការស្ងប់រំងាប់ជាដើម ។

៦៤- ម្ដាយឪពុកសោកណា ស្រឡាញ់ស្ងួនភ្ងា
ហៅក្នុងសង្សារ អាចមកបំបួស ហេតុចង់សម្ភារ
ប្រើបង់អន្ធពាល រៀនដោយក្រមច្បាប់ ។

ធម្មជាតិជាឪពុកម្ដាយ រមែងមានធម៌សប្បុរសស្រឡាញ់ គ្រប់គ្រងថែរក្សាបុត្រ ប្រកបដោយព្រហ្មវិហារធម៌ ៤ ប្រការគឺ មេត្តា, ករុណា, មុទិតា, ឧបេក្ខា ។ លោកទាំងពីរនេះ មានចិត្តសោមនស្សត្រេកអរ តាំងតែពីថ្ងៃដែលដឹងថា កូនមកចាប់បដិសន្ធិក្នុងគភ៌ម្ដាយ ម្ដាយបានលំបាកយ៉ាងណា ក៏ខំធន់ទ្រាំថែទាំខ្លួនឲ្យល្អ ដោយប្រាថ្នាឲ្យកូននោះមានជីវិតគង់នៅ ។ លុះកូនសម្រាលមកកាលណា មាតាបិតាក៏ប្រឹងបីបាច់រក្សាទារកនោះ ដោយព្រហ្មវិហារធម៌ មានចិត្តអំណរនឹងកូន បានសុខចំរើន នឹងជ្រាបសេចក្ដីស្រោះស្រើទៅរកកូន ដោយអំណរចចិត្តស្រឡាញ់ អាណិតកូនយ៉ាងនេះ កាលកូនចំរើនធំពេញរូបកាយ ហើយក៏បេកទៅបំបួសក្នុងព្រះពុទ្ធសាសនា ព្រោះ "ហេតុចង់សម្ភារ" បានសេចក្ដីថា មាតាបិតា ខ្លាចក្រែងកូនពុំស្គាល់បុណ្យទូវបាប ពុំស្គាល់អំពើសុចរិតនឹងទុច្ចរិត, ទើបឲ្យបួស ដើម្បីនឹងផ្ដុំឲ្យទូវកងកុសល នឹងសុចរិតធម៌ កុំឲ្យធ្លាក់ទៅកាន់អបាយភូមិទាំង ៤ ហើយប្រើឲ្យរៀនទូវក្រមច្បាប់ ប្រយោជន៍ឲ្យលះបង់អំពើអន្ធពាល ។

(គាថាទៀត លោកខ្ទុទ្ទានថា)

សង្វាតសរសេរ អស់អញកុំខ្ជិល ទើបបានជាគាប់
សង្វាតសូត្ររៀន ដោយត្រូវប្រញាប់ កុំធ្វើលេលាប់
ដោយចិត្តមាត់ង៉ាយ ។

គឺឱ្យកូនខ្វល់ខ្វាយខ្នះខ្នែង រៀនធម៌ចំរើនមេត្តាភាវនា ជាផ្លូវទៅកាន់សេចក្ដីសុខ ដ្បិតឃើញថាបណ្ដាអ្នកជាពហូស្សូត ជាអ្នកចេះដឹងច្រើន តែងស្គាល់ខុសនឹងត្រូវ ចៀសវាងវៀរចាកបាបកម្ម ឲ្យរួចផុតអំពីអំពើពាលា, ចេះច្បាប់ព្រះពុទ្ធ ហើយប្រព្រឹត្តបដិបត្តិតាម ឥតលំអៀង, កូននោះនឹងបានជាមនុស្សវិសេសក្នុងលោកនេះ និងលោកឯមុខ ដោយផលដែលចេះដឹង អាចលះបង់ពាលអាក្រក់ អស់ចេញអំពីសន្តានចិត្ត ។

មិនតែប៉ុណ្ណោះទេ ខ្ទុនានឲ្យហាត់សង្វាតរៀនតាមត្រីប្រញាប្ដ ឲ្យខំហាត់សរសេរអក្សរតាមវិធីអក្ខរៈ ឲ្យត្រឹមត្រូវតាមក្បួនខ្នាត, ហាមមិនឲ្យខ្ជិលច្រអូស មិនឲ្យធ្វើខ្ជះខ្ជាះប្រមាថមាក់ងាយវិជ្ជាទាំងនោះឡើយ, សង្ឃឹមថាបើកូនមានសុភាព ទទួលធ្វើតាមពាក្យប្រដៅទាំងនោះបាន ហើយ កូននឹងបានជាគាប់ ពេញបញ្ញាលជាបណ្ឌិតជាតិ ១ ដែលគេតែងរាប់អានគ្នា ។

ដូច្នេះឃើញថាឪពុកម្ដាយ ស្រឡាញ់អាណិតកូនខំយកយោងកូនឲ្យរួចអំពីទីអសោចិ៍លាមក ហើយនឹងបានសុខទាំងជាតិនេះនិងជាតិមុខ ។

៩៥- ហៃអស់សាមណេរ ម្តាយមកបន្ទោរ អ្នកជា
ទាឡាយ សង្វាតសូត្ររៀន ដូចលោកទាំងឡាយ
កុំធ្វើពាលរាយ ដូចនៅគ្រហស្ថ ។

បទនេះបានសេចក្តីថា តាំងពីព្រះពុទ្ធអង្គគង់ព្រះជន្មនៅ រហូតរៀងរហូតមក ពួកពុទ្ធបរិសទ្យដែលមាននិស្ស័យនឹងព្រះរតនត្រ័យ តែងតែនាំកូនចៅទៅបួស ពីកូនតូចៗដែលមានអាយុពី ៧ ឆ្នាំទៅ ដល់នឹងអាយុ ១៩ ឆ្នាំ ឲ្យបួសជាសាមណេរ, បើអាយុគ្រប់ ២០ ឆ្នាំ បរិបូណ៌ហើយ ឬច្រើនកើនឡើងទៅ ឲ្យបួសជាភិក្ខុ ។

កាលកូនបួសជាសាមណេរហើយ ត្រូវពុកកូនទេះថា "ហៃអស់សាមណេរ ម្តាយមកបន្ទោរ អ្នកជាបាឡាយ" បានសេចក្តីថា សាមណេរអើយ! អ្នកបួសជាសាមណេរហើយ ម្តាយយកអ្នកមកបន្ទោរ ប្រគេនលោកគ្រូអាចារ្យឧបជ្ឈាយ៍ សូមឲ្យលោកមេត្តាឧបត្ថម្ភអ្នក, លោកទទួលភារៈបង្ហាត់បង្រៀន ទូន្មានណែនាំវិជ្ជាផ្សេងៗ ដូច្នេះ ចូរសាមណេរ "សង្វាតសូត្ររៀន ដូចលោកទាំងឡាយ កុំធ្វើពាលេអាយ ដូចនៅគ្រហស្ថ" បទខាងចុងនេះ គឺគ្រាន់តែជាសេចក្តីថែមទៀតថា ឲ្យកូនសិស្សខំព្យាយាមប្រឹងប្រែងរៀនសូត្រ ដូចលោកបរិស័ទទាំងឡាយ ដែលជាអ្នកបួសនៅអាក់សជន៍គ្នា ឲ្យយកដំរាប់តាម

កុំធ្វេសប្រហែសខ្វះប្រាណ គង់គិតគ្រប់ជំពូក កុំប្រព្រឹត្តក្រៅពាក្យសិក្ខា កុំគប្បីធ្វើខ្ជិលជួបទៅជាគ្រហស្ថនោះ ។

ប៉ុណ្ណោះក៏ពុំស្រេច ត្រូវនៅមានសេចក្តីកង្ខា ដែលកូនសិស្សពុំលុះតាមដំបូន្មាន ក៏ប្រដៅតទៅទៀតថា ។

កុំធ្វើរាយមាយ ជីងគ្រូចាញ្ញាយ ទុកស្មើអម្ចាស់
សង្វាតសរសេរ សូត្ររៀនឲ្យណាស់ ទ្រាំផ្ញាយល់ច្បាស់
នាំញាតិតាំងឆ្ងាយ ។

បានសេចក្តីថា គ្រូហាមប្រាមប្រាប់កូនសិស្ស កុំឲ្យព្រហើនធ្វើឫកពា តយើនជាក្មេងមាត់ទីងគ្រូច្បាយ ត្រូវគោរពប្រណិប័តន៍លោក ទុកស្មើនាយចៅហ្វាយ ហើយឲ្យសង្វាតខំឃាត់រៀនសូត្រ អំពីសំណាក់លោកឲ្យបានច្រើន ដើម្បីឲ្យកើនចំណេះ ចេះដឹងឲ្យច្បាស់លាស់វែកញែក យល់ការខុសត្រូវ ប្រសប់ឆ្លាតវៃ គង់គិតទាំងពួងជាប្រយោជន៍ ទីង "នាំញាតិតាំងឆ្ងាយ" ។

ឯសំដីតាំងប៉ុណ្ណេះ មានដំណើរសេចក្តីទៅថា បើកូនសិស្សណារៀនចេះ មានចំណេះគ្រប់គ្រាន់ ទាំងគតិលោកនិងគតិធម៌ ហើយញាតិទាំងឡាយនឹងបានជាទីពឹងវាក្រស័យ ដោយប្រយោជន៍យ៉ាងសំខាន់ ៣ ប្រការ ១– គឺមានអ្នកចេះដឹងនេះហើយជាអ្នកទាំមុខ យកយោង

ពន្យល់ មិនឲ្យគណញាតិប្រព្រឹត្តល្មើសព្រះពុទ្ធបញ្ញត្តិឲ្យបានសុខក្នុង ជាបច្ចុប្បន្ន ដែលមានជីវិតរស់នៅ ។

២- គឺទូន្មានញាតិឲ្យស្គាល់បាបបុណ្យគុណទោសខុសត្រូវ តាមពុទ្ធានុសាសនី លុះរលាយខន្ធទៅ នឹងបានទៅកាន់សុគតិ ។

ហេតុនេះយុវជនទាំងឡាយ គប្បីខំប្រឹងប្រតិបត្តិកុំឲ្យឃ្លាតឡើយ អំពីពាក្យទូន្មាន ។

៩៦- អាសូរមេធា ចិញ្ចឹមរក្សា កុំឲ្យអន្តរាយ
អាចយកមកធ្វើ នឹងត្រូវបាព្យាយ ហេតុចង់ពណ្ណរាយ
ប្រយោជន៍ទាំងពីរ ។

ពាក្យដែលថា "អាសូរមេធា ចិញ្ចឹមរក្សា កុំឲ្យអន្តរាយ" ដូច្នេះ ជាដើមបទនេះ គឺលោកថាឲ្យកូនសិស្សយកចិត្តអាណិតអាសូរករុណា អាពុកម្តាយ ដែលជាបុព្វការី បីបាច់ថែទាំចិញ្ចឹមរក្សា តាំងពីកើតមក ទាល់ធំប៉ុណ្ណេះ ឲ្យបុត្រមានសេចក្តីកតញ្ញូ លំទុកលំទុនអង្គ ដូងចិត្ត ប្រព្រឹត្តតាមឱវាទដែលលោកប្រដៅមកទាំងប៉ុន្មាន កុំឲ្យអន្តរាយក្បួន ភ្លាត់បាត់អសារឥតការទៅឡើយ ។

តមកទៀតលោកប្រាប់ថា "អាចយកមកធ្វើ នឹងត្រូវបាព្យាយ ហេតុចង់ពណ្ណរាយ ប្រយោជន៍ទាំងពីរ" ពាក្យនេះពន្យល់បង្ហាញកូនសិស្សឲ្យឃើញនូវបំណង ដែលម្តាយប្រាថ្នាហើយហ៊ានយកកូនមក

ទុកឲ្យនៅទីងលោកគ្រូអាចារ្យ ក៏ព្រោះចង់ឲ្យកូនបានចម្រើនរុងរឿង មាន កិត្តិសព្ទកិត្តិយស ល្បីខ្ចរខ្ចាយសាយទួទៅ ដោយកូនមានចំណេះវិជ្ជា យ៉ាងក្រាស់ក្រែល ទីងបានបម្រើនូវប្រយោជន៍ទាំង ៣ ប្រការក្នុងនា លោកិយនេះ គឺឲ្យចេះច្បាប់នេះ ១, ឲ្យមានប្រាជ្ញាឈ្លាសវៃនេះ ២, ឲ្យ មានបារមីនេះ ៣ ។ (ប្រយោជន៍ទាំង ៣ នេះ ទីងបរិយាយនៅ ខាងក្រោយ) យកសេចក្តីទាំងពីដើមមកត្រឹមណេះ រួបរួមគ្នាឡើងឃើញ ថាមាតាបិតាជាមគ្គនាយករបស់បុត្រធីតា ព្រោះលោកប្រកបដោយ សប្បុរសធម៌ គ្រប់គ្រងកូនគ្រប់ជំពូកឥតឲ្យខ្វះ ចង់ឲ្យតែកូនបាន ជាធំ ចង់ឲ្យតែកូនបានសុខ ទើបត្រេកអរ បើដឹងថាកូនណាបានសេចក្តី ទុក្ខវេទនា ម្តាយឪពុករមែងមានទុក្ខទោមនស្សក្រៃម ជួនមានទាំង ជលនេត្រហូរហោមលោកយំដោយសារតែកូន ។

យ៉ាងនេះ បួរអ្នកទាំងឡាយ កុំគប្បីទីងទីងពាក្យរបស់មាតាបិតា ពោលប្រដៅនោះឡើយ ទោះបីជួបចត់យ៉ាងណា ក៏សុខចិត្តស៊ូជាពាក្យ ពារបំប្រសើរទាំងអស់ ។

៦៧ – ម្លួយចង់ត្រូវច្បាប់ ឲ្យចានខ្ជួនគាប់ ណៅ
ណាលោកិយ ម្លួយចង់ច្រាជ្ញា មិនឲ្យអប្រិយ៍ ម្លួយ
ចង់ចាំរដី ណាំញាតិនាំងឡាយ ។

(មានត)

# ព្រះសមុហ៍ឃោសាចារ្យ យូរ-ប៊ុណ្ណ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង

(តមក)

ហើយទើបស្រែកសួរថា ឱលោកណាអើយមកផ្តាច់ ជីវិតខ្ញុំឲ្យដាច់ ខាន
បីបាច់អ្នកមានគុណ ។ អ្នកជាក្សត្រឬព្រាហ្មណ៍ មានគោត្រនាមឬ
អ្នកបុណ្យ មកនៅទីនេះមុន សូមព្រះគុណប្រាប់ឲ្យច្បាស់ ។ ខ្លួនខ្ញុំ
ជាតិជាមនុស្ស មិនដែលទ្រុស្តដល់ក្មេងចាស់ ទាំងសត្វព្រៃច្រើនណាស់
ឥតមានទាស់ដល់ថ្នាំងថ្នាក់ ។ ឥឡូវលោកមកបាញ់ កូនសំឡាញ់
ជនពីរនាក់ សុទ្ធតែជាអ្នកខ្វាក់ ធ្វើឲ្យអាក់ក្តីព្យាយាម ។ ឬមួយលោក
ត្រូវការ នូវអាហារត្រង់សាច់ឈាម ម្តេចឡើយមកបាញ់សាម មិន
ត្រូវតាមគន្លងធម៌ ។ លោកអើយលោកឈ្មោះអ្វី ចូរស្រដីដោយស្មោះ
សរ ប្រាប់មកតាមនាមករណ៍ ខ្ញុំត្រេកអរសាទរក្រៃ ។ ឯស្តេចបិល-
យក្ស មានយសស័ក្តិវិសេសថ្លៃ ទើបចេញចាកពីព្រៃ ត្រាស់តបវៃ
យ៉ាងនេះថា ។ ខ្លួនយើងនេះជាស្តេច គេសរម្រេចតាមវាចា ជាតួអង្គ
ក្សត្រា បិតុនៅនាដែនកាសី ។ ចេញចាកពោលនគរ ព្រោះរីករវៃ
ចំណី ស្វែងរកសត្វបក្សី ពោលបុរីមិនទឹកនា ។ ចេះសិល្បធ្នូប្រាកដ
តាមបែបបទផ្លូវវិជ្ជា ដើរបាញ់សត្វនានា ដូចប្រាថ្នាចិត្តប៉ុនប៉ង ។

ពោះសត្វនោះតូចក្តី ឬធំដែរចម្បង ៗ សត្វណាឯទៀតជន តាមបំណង យើងប្រាថ្នា ។ ឥឡូវយើងសួរអ្នក ស្រស់លក្ខណ៍ឈ្មោះអ្វី ទាំងមាតាបិតា នៅទីណាជិតឬឆ្ងាយ ។ កាលនោះពោធិសត្វ បុរសត្ត បង្គំថ្វាយ ទូលស្តេចតាមបរិយាយ ទាំងមានកាយដេកផ្ទាល់ដី ។ ទូលបង្គំជាខ្ញុំ បុត្រឧត្តមនៃឥសី គេហៅទាំងប្រុសស្រី ដោយមេត្រីជាសាមា ។ បិតាទូលបង្គំ នៅបួសជុំនឹងមាតា អាស្រ័យគង់សាលា មាននេត្រាសុទ្ធតែខ្វាក់ ។ នឹងទៅណាពុំបាន ទាំងពីរប្រាណព្រួយឥតអាក់ មានតែកូនមួយនាក់ គ្រាន់នឹងថ្នាក់ថ្នមបំរើ ។ ថ្ងៃនេះព្រះអង្គបាញ់ កូនសំឡាញ់ស្លាប់ហើយតើ បាននរណាបំរើ ប្រាកដស្មើដូចជាខ្ញុំ ។ សូមទ្រង់ទតមើលចុះ ខ្លួនធ្លាយធ្លុះឈាមជុំៗ ត្រង់សរមួលត្រសុម ពិសពាប់ជុំវិញខ្លួនហើយ ។ ព្រះមហាសត្វថ្ងៃថ្វា ឈឺខ្លោចផ្សាទុក្ខឥតស្បើយ ថានុខ្លួនអញអើយ ថ្ងៃនេះហើយស្លាប់មិនខាន ។

## ពិរោះបទសុវណ្ណសាម

ពាក្យ ៧

ឱព្រះមាតាបិតាអើយ ពានេះទៅហើយអស់ទីពឹង ឥតមាននរណាជាទីពឹង គំនាក់គ្រាន់ពឹងទៅថ្ងៃមុខ ។ ពីដើមបានកូនបម្រើ

រកផ្លែមើមឈើសន្សំទុក ជាគ្រឿងអាហារមានគ្រប់មុខ ឆាន់តែអផ្សុក សោះព្រួយព្រាណ ។ ទឹកស្រង់ទឹកឆាន់មិនខ្វះខាត ទីសឹងស្អាតមិនសល់ខាន ពេលថ្ងៃកូនរៀនធម៌សម្រាន្ត ពេលយប់កូនបានគក់ច្របាច់ ។ ថ្ងៃនេះកូនដល់មរណាហើយ ទូម្ចាស់ថ្ងៃអើយកម្មមកផ្ដាច់ ឲ្យខានធ្វើកិច្ចការបីបាច់ ឥឡូវកូនត្រាច់ចោលកន្ទ្វង ។ ម៉្លេះសមគាត់ចាំមើលផ្លូវកូន មកបាត់ឈឹងសូន្យរឹងចម្បែង ស្រែកហៅរកកូនព្រួតក្ដែងៗ ប្រឹងស្ទាបដើរស្វែងរកគ្រប់ច្រក ។ តាំងពីរសៀលដល់ព្រលប់ ឥតមានឈរឈប់ទំរុករក តាមផ្លូវដែលធ្លាប់ដើរទៅមក ទីងទីធ្លាប់ជ្រករកគ្មានសល់ ។ ទុម្ម៉េះសមគាត់ព្រួយលំបាក ប្រឹងរកមិនស្រាកទុក្ខកង្វល់ អព្រាត្រយប់ស្ងាត់យំសោកដល់ កូនប្រុសទំល្មមិនឃើញមក ។ ទុម្ម៉េះសមគាត់ស្លាប់អស់អារ ព្រោះអត់អាហារគ្មានអ្នករក សង្ស័យពួកញាតិគ្មានមកជ្រក ទឹងហៅកប់រកជួយការពារ ។ ខ្ញុំអញនេះស្លាប់មិនសូវស្ដាយ ព្រួយតែពុកម្ដាយអន្ធការ ពីថ្ងៃនេះទៅអត់អាហារ ផ្ដាច់ចោលសង្ខារជាមិនខាន ។ ទុលោកណាទៅទីនេះអើយ ឥតពីខ្ញុំហើយសូមស្មោះស្ទាន មេត្តាសង្គ្រោះជនពីរប្រាណ ឲ្យលោកស្រោកស្រាន្តសៀយទុក្ខា ។ អស់ពួកទេវតារក្សាព្រៃ បើកនេត្រនៃដោយមេត្តា សូមលោកជួយថែទាំរក្សា មាតាបិតាខ្ញុំឲ្យបាន ។

## បទព្រហ្មគីតិ

កាលនោះស្ដេចបិលយក្ស ចិត្តស្មោះស្ម័គ្រដោយមេត្រី លុះឮពាក្យសំដី ត្រាស់ទៅខ្ញីថាសាមអើយ ៗ ចូរអ្នកកុំផារម្ភ កិច្ចនេះខ្ញុំធា· នាហើយ បំរើមិនគោះគើយ ឲ្យបានស្បើយដូចប្រាថ្នា ៗ អ្នកប្រាប់ទីលំនៅ បិតាពៅនៅត្រង់ណា នឹងព្រះវរមាតា ខ្ញុំយាត្រាត្រង់ទីនោះ ៗ ព្រះម៉ហាសត្វថ្លៃថ្លា បើកនេត្រាមើលចំពោះ ឮថាស្ដេចសគ្រោះ ទូលទៅឆ្ពោះប្រាប់កន្លែង ៗ បពិត្រព្រះកជា ស្ដេចលីលាផ្លូវនេះឯង មិនមានត្រៃឡែងកែង ផ្លូវត្រង់វែងចុះដើរម្នាក់ ៗ បើស្ដេចយាងទៅដល់ ទ្រង់ពន្យល់ឲ្យដឹងជាក់ កុំឲ្យលោកអន់អាក់ ខ្លាចភ័យភ្ញាក់ដល់តក់ស្លុត ៗ កិច្ចការទាំងប៉ុន្មាន ទ្រង់ស្មោះស្មានធ្វើបំផុត រំពឹងលើឧមមកុដ ឲ្យបរិសុទ្ធផុតសង្ស័យ ៗ ហើយសូមទ្រង់មេត្តាជំកបថាកូនក្សិណក្ស័យ កុំឲ្យត្អូញព្រះទ័យ ទឹកអាល័យបុត្រកំសត់ ៗ កូនសូមបង្គំលា ទីងមរណាជាប្រាកដ ថ្ងៃនេះដល់កំណត់ សូមលោកអត់ទោសឲ្យបាន ៗ

## ពិហេបស្ដេចបិលយក្ស

### ពាក្យ ៧

គ្រានោះព្រះបាទបិលយក្ស កើតព្រះត្រៃលក្ខណ៍ក្នុងសន្ដាន យល់ច្បាស់ថាទសត្វពល់ប្រាណ មុខជានឹងបានបាស់ឈឺស្លាប់ ៗ

ទើបស្តេចទ្ញញទ្រង់ព្រះកន្សែង ទឹកដល់ខ្លួនឯងធ្វើមិនបាប់ កាលដើមរៀនមកមិនដែលធ្លាប់ ដឹងថាសត្វស្លាប់ជាធម្មតា ។ ឥឡូវមកឃើញសាមបណ្ឌិត នេះគួរឲ្យគិតដល់អាត្មា ដឹងរស់នៅហើយបាន ត្រឹមណាស្លាប់ពោលកាយានោះទៅវិញ ។ ដូចជាសុវណ្ណសាមកុមារ ទើបទឹងថ្លែងការណ៍អម្បាញ់មិញ ឥឡូវគាត់ស្លាប់បាត់ទៅវិញ រកទ្រព្យលោះវិញក៏ពុំបាន ។ អាត្មាអញធ្វើកម្មអាក្រក់ ទឹងទៅនរកជួនពុំខាន សោយទុក្ខវេទនាឥតស្រាកស្រាន្ត ព្រោះចិត្តក្លាហានដោយមោហា ។ បើខ្លួនអញនៅក្នុងនគរ ពួកមនុស្សឈ្មួញគេពោលថា មិនសមបើអង្គព្រះក្សត្រា ធ្វើកម្មពេកយ៉ាងនេះសោះ ។ ចុះបើមកនៅក្នុងព្រឹក្សព្រៃ គ្មានអ្នកដទៃពោលចំពោះ ឲ្យអញបានឮពាក្យពិរោះ ឬពាក្យទ្រគោះនោះសោះឡើយ ។

## និយាយពីនាងទេពធីតា បទព្រហ្មគីតិ

គ្រានោះទេពធីតា[1] ឋិតនៅនាគន្ធមាទន៍ ដឹងថាស្តេចពិយាដនូវផនជាតិមនុស្សព្រៃថ្លា ។ ទើបត្រាច់ពីទីនោះ មុខចំពោះមកក្សត្រា ពោលនូវបទគាថា ដោយវាចាយ៉ាងនេះឯង ។ បពិត្រព្រះរាជា បានឮថាទ្រង់ឥតក្រែង ធ្វើបាបមិនស្រប់ស្រែង សត្វកន្ទែងឥតលស់លា ។

---

១ នាងទេពធីតានេះ ធ្លាប់ជាមាតាពោធិសត្វក្នុងបុព្វជាតិទី ៧, លុះដល់ច្យុតមកកើតក្នុងទីនេះ តែងរក្សាពោធិសត្វសព្វ ថ្ងៃតរៀងមក ។

ដូចយ៉ាងជនបីនាក់ គ្មានថ្នាំងថ្នាក់ក្នុងចិន្តា ជាជនឥតទោសា ម្តេច ក្សត្រាមកសម្លាប់ ៗ បើដូច្នោះសូមព្រះអង្គ យាងត្រាច់ត្រង់ទៅប្រញាប់ ធ្វើបុណ្យឲ្យឆាប់ៗ ខ្ញុំនឹងប្រាប់នូវសួគ៌ា ៗ ចិញ្ចឹមពួកជនខ្វាក់ ទាំងពីរ នាក់ឲ្យដូចជា សុវណ្ណសាមបុត្រា ទើបក្សត្រាចាកអបាយ ៗ ព្រះ រាជាអង្គនោះ ក៏ត្រេកត្រមក្រោះទ្រង់សោកស្តាយ ពោធិសត្វចេតឆាយ មានរូបកាយស្រស់ប្រិមប្រិយ ៗ កណ្តៀតក្អមយាងទៅ ព្រោះសំដៅ ត្រង់កុដិ សូរជើងធ្ងន់ឥតបី ខ្ឃាតខ្ទីដល់សាលា ៗ ទើបទុកូលបណ្ឌិត ទំពិនិត្យសួរទៅថា សទ្ទឹកជើងនរណា មកប្រាថ្នាដើម្បីអ្វី ៗ ដើរ នេះតាមទំនើង មិនមែនជើងកូនពិសី ជាតិជាមនុស្សមកថ្មី ចូរស្រដី ប្រាប់ខ្ញុំផង ៗ ស្តេចតបទៅវិញថា ខ្ញុំនេះណាជាចម្បង លើស អស់ពួកអ្នកផង នៅត្រប់ត្រងដែនកាសី ៗ លះបោលរាជសម្បត្តិ ស្វែង រកសត្វក្តង់អដរ៍ បរិភោគជាចំណី ពេលស៊ីមិនទឹកនា ៗ ឯទុកូល បណ្ឌិត កសីសិទ្ធចិត្តមេត្តា ឮហើយកើតជ្រះថ្លា ចង់ប្រាថ្នាធ្វើកុសល ៗ ទើបទូលបង្គំថា ព្រះករុណា សូមសោយផល ដែលខ្ញុំបានដកល់ បង្រួមដល់ពេលខាងមុខ ៗ មាក់ប៉ែនមៀនស្រគំ ទន្ទាប់ទុំប្រមូល ទុក ស្វាយបេកតាន់ត្រប់មុខ សោយឲ្យសុខតាមសប្បាយ ៗ ព្រះ រាជាសួរថា ផ្លែឈើទាំងឡាយ អ្នកណានាំពីឆ្ងាយ មកដល់អាយ រៀបទុកជាក់ ៗ បើលោកទាំងពីរប្រាណ ទៅមិនបានសុទ្ធតែខ្វាក់

ម្តេចឡើយទើបដឹងជាក់ បេះបានដាក់ក្នុងកញ្ជើ ។ ទុកូលបណ្ឌិតថា សាមបុត្រាបេះទេតើ ផ្លែឈើនឹងមើមឈើ ដើររុករើក្នុងព្រៃព្រៃ ។ ទៅរកមិនដែលខាន សន្សំបានតែរាល់ថ្ងៃ មកទុកគ្រាន់សំរៃ ជាកម្រៃទៅពេលព្រឹក ។ កាលបុត្រវិលមកដល់ ទំនាយខ្វល់ទៅដងទឹក សម្រាប់ឪនិងពុកផឹក តាមចិត្តទេកចង់ពេលណា ។ ឥឡូវកូនមិននៅ កាន់ក្អមទៅឯអគ្គា រសៀលតាមសុរិយា ផុតវេលាវិលវិញហើយ ។ ព្រះពជាអង្គនោះ តបចំពោះថាលោកអើយ លោកកុំព្រួយចិត្តឡើយ ខ្ញុំនេះហើយទឹងរក្សា ។ រីឯសាមបណ្ឌិត រូបល្អពិតគួរទស្សនា ខ្ញុំបានផ្តាច់ជីវ៉ា ដួលដេកនាលើផ្លូវខ្សាច់ ។ ឯនាងបារិកា បានឮថាកូនបីបាច់ ជីវិតស្តេចបានផ្តាច់ ញ័រសព្វសាច់អស់អង្គា ។ ស្ទុះមកកាន់អាស្រម ឥសីសមនិយាយថា ខ្លួនយើងរស់ពីណា ស្លាប់តាមគ្នាទៅគ្រាន់បើ ។ កូនយើងបាត់ទៅហើយ រស់ចុះឡើយឥតអំពើ មិនមានអ្នកណាធ្វើ កិច្ចបំរើដល់យើងខ្ញុំ ។ ទុកូលតបទៅថា នែបារិកាកុំអន់អាក់ បង្កើតចិត្តចាំងថ្នាក់ ឲ្យចំពាក់កម្មវេរ ។ ព្រះអង្គគានបំណាំង នឹងប៉ុនប៉ងផ្តាច់ជីវ៉ា បុត្រប្រុសស្រស់ពុំងា ដោយពាលាចិត្តកំហឹង ។ ឥឡូវមកប្តេជ្ញា អង្គលោកថានឹងទំព្រឹង បីបាច់ជាពំនឹង ឲ្យយើងពឹងមួយជីវិត ។ នែនាងបារិកា បុត្រថ្ងៃថ្លាយើងកុំគិត កុំឲ្យខ្វះចំនិត ក្រែងបណ្ឌិតលោកនិន្ទា ។ (មានត)

## បរិយាយសិប្បកថា

## ព្រះគ្រូសុវណ្ណញាណ សូរ-ហាយ រៀបរៀង

(តមក)

១-ហត្ថិសិប្បៈ សិល្បៈក្នុងវិធីបង្ហាត់ដំរី ត្រួតត្រាខាងពលដំរី ។

២-អស្សសិប្បៈ សិល្បៈក្នុងវិធីទូន្មានសេះ ត្រួតត្រាខាងពលសេះ ។

៣-រថសិប្បៈ សិល្បៈក្នុងការធ្វើរថ ត្រួតត្រាខាងពលរថ ។

៤-ធនុសិប្បៈ សិល្បៈក្នុងការបាញ់ធ្នូ ប្រសប់ខាងកាន់ធ្នូ ។

៥-ថរុសិប្បៈ សិល្បៈក្នុងការប្រើអាវុធ កសាងអាវុធ ។

៦-មុទ្ទាសិប្បៈ សិល្បៈក្នុងការរាប់កាញ់គ្នេរដោយដៃទទេ ។

៧-គណនាសិប្បៈ សិល្បៈក្នុងការកាន់បញ្ជីកត់ត្រារាប់ចំនួនមនុស្សនឹងវត្ថុផ្សេងៗ ។

៨-សង្ខានសិប្បៈ សិល្បៈក្នុងការប្រើឧបាយប្រាជ្ញាក្នុងផ្លូវសាសនោបាយ ។

៩-លេខាសិប្បៈ សិល្បៈក្នុងការសរសេរនឹងវិធីប្រើអក្សរត្រូវតាមច្បាប់អក្សរសាស្ត្រ ។

១០-កាវេយ្យសិប្បៈ សិល្បៈក្នុងការតែងពាក្យកាព្យឃ្លោងនឹងប្រវត្តិសាស្ត្រផ្សេងៗ ។

១១- លោកាយតនសិប្បៈ សិល្បៈក្នុងផ្លូវលោកមានវិជ្ជាពេទ្យ ទឹងវិជ្ជាមើលលក្ខណៈផ្សេងៗ ជាដើមព្រមទាំងបរមត្ថវិជ្ជា ទឹងវិធីផ្សំធាតុញែកធាតុរកដើមកំណើតឲ្យឃើញប្រាកដ ។

១២- ខត្តិវិជ្ជាសិប្បៈ សិល្បៈក្នុងក្រសួងរដ្ឋបាល-តុលាការ ច្បាប់ត្រួតត្រាប្រជារាស្ត្រ ។

សិល្បៈ ទាំង ១២ យ៉ាងនេះ គេលើកថាជាវិជ្ជាជាន់ខ្ពស់ក្នុងសាលាទិសាបាមោក្ខ សម្រាប់ប្រទេសជាតិរបស់គេ, ព្រោះគេយល់ច្បាស់ថា ប្រទេសជាតិដែលបានចំរើនរុងរឿងឡើង ក៏ព្រោះអាស្រ័យសិល្បៈទាំងនេះឯង, មួយទៀតសិល្បៈនេះជាផ្លូវសម្រាប់រក្សាគ្រប់គ្រងប្រទេស ឬថាជាលំអរបស់ប្រទេស ។ សិល្បៈក្រៅពីនេះក៏នៅមានច្រើនបែបទៀតណាស់ ប៉ុន្តែគេរាប់ថាជាសិល្បៈសាធារណៈ ខាងផ្លូវពាណិជ្ជកម្ម សម្រាប់របរចិញ្ចឹមជីវិតផ្ទាល់ខ្លួនម្នាក់ៗ ប៉ុណ្ណោះ ។

សិល្បសាធារណៈមាន៩យ៉ាងគឺ

១- ទារុសិប្បៈ សិល្បៈខាងគ្រឿងឈើ គឺការឈ្លាសវៃក្នុងការអារចាំងឈើសង្ហាក់ក្រឡឹងឆ្លាក់បន្ទាត់ ធ្វើផ្ទះសម្បែងទាំងប្រដាប់តាក់តែងផ្ទះមានតុតាំងជាដើម ។

២- ចិត្តកម្មសិប្បៈ សិល្បៈខាងការគូរគំនូរផ្សេងៗ មានគំនូររូបមនុស្សជាដើម ។

៣- សុធាកម្មសិប្បៈ សិល្បៈខាងការជាងកំបោរដីឥដ្ឋគឺប្រសប់ក្នុងការរៀបចំផ្សំផ្គុំដោយគ្រឿងកំបោរដីឥដ្ឋថ្ម ធ្វើបានទាំងផ្ទុកសាងកំផែងប្រាសាទចេតិយផ្ទះ ខាងចល្លិកាវលិត្តកម្ម គឺការលាបបូកឲ្យជិតស្និទ្ធឲ្យមានពណ៌ទាំងខាងក្នុងខាងក្រៅ, ខាងលេបនកម្ម គឺការឆ្លាក់ក្បាច់ក្បូរផ្សេងៗ ។

៤- លោហធាតុសិប្បៈ សិល្បៈខាងការលោហធាតុ គឺប៉ិនប៉ើក្នុងការលៃលកផ្សំធាតុដែក ស្ពាន់ លង្ហិន សំណ ប្រាក់ មាស, គាប់យកលោហធាតុទាំងនោះមកដុត ស្ល រំលាយ ដំ ផែ សិត្ត ស្ទូន ក្រឡឹង រុះរើរៀបចំផ្សំផ្គុំផ្កាសំបូរគ្រឿងយន្ត ឬធ្វើបរិក្ខារសម្រាប់ប្រើប្រាស់ដោយលោហធាតុ ។

៥- វត្ថសិប្បៈ សិល្បៈខាងការត្បាញសំពត់ស្លៀកពាក់រំលេចពណ៌ច្រើនបែបគឺស្ទាត់ជំនាញក្នុងតន្តវាយកម្ម ការត្បាញរវៃអំបោះសូត្រ, ឆេទនកម្ម ការហែក កាត់, សិព្វនកម្ម ការដេរប៉ាក់, រជនកម្ម ការជ្រលក់ឲ្យមានពណ៌គ្រប់យ៉ាងតាមប្រាថ្នា ។

៦- ចម្មសិប្បៈ សិល្បៈខាងការស៊ុំស្បែក គឺវិធីសំឡាប់ស្បែកឲ្យមានសាច់ទន់ស្អាតល្អ ធ្វើបរិក្ខារសម្រាប់ប្រើប្រាស់ដោយស្បែកសត្វផ្សេងៗ ។

៧- នហាបិតសិប្បៈ សិល្បៈខាងការកាត់សក់ លាបសក់ កក់តែងសក់ឲ្យល្អតាមសម័យ ។

៨- មណិការសិប្បៈ សិល្បៈខាងវិធីធ្វើត្បូងតីបេះប្រែសប់ខាងការឆ្នៃត្បូង-ពេជ្រ, ស្វៃរផ្សេង ៗ មានកែវមណីជាដើម ។

៩- តិលញ្ឆសិប្បៈ សិល្បៈខាងរបៀបតម្បាញកន្ទេល, ផែងឬល្អិចង្អេរជាដើម ។

សិល្បៈទាំងអស់ដូចសំដែងមកនេះ ហាក់ដូចជារំគាប់រំគោចរប៉ិចរប៉ុ ប៉ុន្តែមិនមែនដូច្នោះទេ គឺជាវិជ្ជាសម្រាប់ដៃរបស់គ្រហស្ថ បម្រើផលការចិញ្ចឹមជីវិតឬជាជាលំអរបស់ត្រកូល; សិល្បវិជ្ជាទាំងនេះ, បើជនជាគ្រហស្ថ ឥតគំនិតមិនបានគិតសិក្សាឬជាមនុស្សខ្ជិលច្រអូសក៏មិនអាចនឹងបានចេះដឹងក្នុងសិល្បៈណាមួយឡើយ ។ បុគ្គលជាគ្រហស្ថប្រុសស្រីដែលមានចិត្តប៉ុនប៉ងក្នុងការស្វែងរកទ្រព្យ ឬបុរសដែលមានចិត្តចំពាក់ក្រាបក្រាញទៅក្នុងយកកាសសម្បត្តិ ក៏ត្រូវតែស្វះស្វែងរករៀនសិល្ប-វិជ្ជាណាមួយឲ្យបានចេះដឹងស្ទាត់ប្រាកដក្នុងខ្លួន ដើម្បីជាស្នាដៃ ជាអលង្ការជាលំអរបស់បុរសស្ត្រីក្នុងត្រកូលនីមួយ ៗ, ព្រោះថាបុរសស្ត្រីដែលមានរូបឆោមស្រស់បស់ល្អយ៉ាងណាក៏ដោយ តែបើគ្មានវិជ្ជាក្នុងខ្លួនហើយនឹងកប់ជាល្អពុំបានឡើយ ប្រៀបដូចជាមនុស្សកំបុតដៃជើងឬដូចជាមនុស្សគ ឬក៏ដូចជាមនុស្សអាក្រាតកាយទទេ ។ សិល្បៈនេះទុក

ជាធុរៈមួយ សម្រាប់ត្រកូលគហស្ថត្រូវទទួលសិក្សា; ឯបុរសស្ត្រីដែលគ្រាន់តែល្អរូបប៉ុណ្ណោះ តែបើមិនមានសិល្បវិជ្ជាផងទេ ក៏គង់មិនល្អខ្ពង់ខ្ពស់ដល់ត្រកូលបាន សមដូចគាថាសុភាសិតថា

"រូបយោព្វនសម្បន្នា វិសាលកុលសម្ភវា
វិជ្ជាហីនា ន សោភន្តិ និគ្គន្ធា ឥវ កឹសុកា" ។

សេចក្តីថា "បុគ្គលកើតក្នុងត្រកូលខ្ពង់ខ្ពស់ បរិបូណ៌ដោយរូបទឹងវ័យនៅក្មេងក៏ដោយ តែបើសាបសូន្យចាកវិជ្ជាហើយ មិនឈ្មោះថាល្អទេ ដូចជាផ្កាចារ (គ្រាន់តែមានពណ៌ក្រហមច្រាល) តែឥតក្លិនក្រអូប" ។

មួយទៀត សិល្បៈនេះទុកដូចជាទ្រព្យធនដើមទុនដែលចាយវាយមិនចេះអស់ ភ្លើងក៏មិនឆេះ ទឹកក៏មិនលិច ទាំងចោរក៏លួចប្លន់យកមិនបាន, សមដូចគាថាសុភាសិតលោកនីតិថា

"សិប្បសមំ ធនំ នត្ថិ សិប្បំ ចោរា ន គណ្ហរេ
ឥធលោកេ សុចំ មិត្តំ បរលោកេ សុខាវហំ" ។

សេចក្តីថា "ទ្រព្យស្មើដោយសិល្បៈ មិនមានទេ ចោរទាំងឡាយក៏លួចយកសិល្បៈមិនបាន សិល្បៈជាមិត្តសំឡាញ់នាំមកនូវសុខក្នុងលោកនេះផង នាំមកនូវសុខក្នុងបរលោកផង" ។

ក្នុងគម្ពីរមង្គលត្ថទីបនី មានរឿងដំណាលថា បីឋសប្បិ (បុរសខ្វិន) ម្នាក់ ចេះស្ទាត់ប្រាកដក្នុងសាឡិតសិប្បៈ គឺវិជ្ជាផ្ទាត់គ្រួស អាចផ្ទាត់

ផ្គុំក្រសត្រូវស្ទូកឈើឲ្យមានរូបដូចជារូបសត្វអ្វីៗ បានទាំងអស់, បុរសខ្វិននោះមានឈ្មោះឮល្បីខ្ចរខ្ចាយ ដោយគ្រាន់តែចេះសិល្បៈផ្គាត់ក្រសប៉ុណ្ណោះ, ដំណាលថា ស្តេចក្នុងនគរនោះ មានបុរោហិតម្នាក់ ជាអ្នកមាត់រឹងនិយាយច្រើនមិនសូវចេះឈប់, លុះស្តេចបានជ្រាបហើយក៏ចាត់រាជបុរសឲ្យទៅនាំយកបុរសខ្វិននោះមកដើម្បីឲ្យផ្គាត់អាចម៍ពពែ ដាក់មាត់បុរោហិត ដែលមានសំដីរឹងនោះធ្វើឲ្យរាងចាល, លុះរាជបុរសនាំមកដល់ហើយ ស្តេចក៏ឲ្យលាក់បំពួនបុរសខ្វិននោះក្នុងកន្លែងជិតស្តេចរួចឲ្យហៅបុរោហិតមក ហើយនាំឲ្យនិយាយ, លុះបុរោហិតហាមាត់និយាយឡើង, បុរសខ្វិនក៏បានឱកាសផ្គាត់អាចម៍ពពែចូលចំមាត់ប្លុកៗ រាល់តែមាត់ដែលបុរោហិតហានិយាយ, ផ្គាត់ឲ្យចូលរហូតដល់ពោះ ទាល់តែពេញពោះព្រាលឡើងមកដល់ដើមកនិយាយលែងកើត, ស្តេចក៏ទ្រង់មានព្រះអំណររួចទ្រង់ប្រទានរង្វាន់ជាច្រើន ព្រមទាំងស្រុកសួយ ៤ ស្រុកថែមទៀត; បុរសខ្វិននោះក៏បានឡើងទៅជាអ្នកមានទ្រព្យស្តុកស្តម្ភគ្រាន់បើមួយរំពេច ដោយវិជ្ជាសិល្បៈផ្គាត់ក្រសនោះឯង ។

គ្រានោះ មហាមាត្យជាបណ្ឌិតរបស់ស្តេច បានសំដែងសរសើរអានិសង្សរបស់សិល្បៈចំពោះព្រះភក្ត្រស្តេច ក្នុងវេលាដែលចូលគាល់នោះ ដោយគាថាសុភាសិតថា:

"សាធុខោ សិប្បកំ នាម អបិ យាទិសិកីទិសំ
បស្ស អជប្បហារេន លទ្ធា គាមា ចតុទ្ទិសា" ។(មានត)

# ឯកការកមិលិន្ទបញ្ហា

## បាឋនិពន្ធមន្ត្រីញ៉ុក-ថែម ប្រែម្រៃប្រែ

(តមក)

## អង្គ ២ របស់សត្វក្អែក:

១ - មានសេចក្តីស្ញៀសសង្ស័យជុំខ្លួនប្រយ័ត្នខ្លួនដើរហើររកស៊ី ។

២ - ជួបប្រទះចំណីណា ទីមួយ គឺសាកសពឬសេសអាហារចំណី ក៏ស្រែកហៅពួកញាតិជាតិក្អែកនាំគ្នាមកស៊ីជាមួយគ្នា ។

ត្រូវបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ គឺ:

១ - មានសេចក្តីវៀរសង្រួមអំពើទុច្ចរិតសព្វមនោទ្វារដោយសតិដ៏ខ្ជាប់ខ្ជួន តាំងចិត្តរក្សាការពារទ្វារទាំង ៦ គ្រប់ឥរិយាបថ ។

២ - បានលាភសក្ការៈយ៉ាងណា ៗ ដែលប្រកបដោយធម៌ ដែលកើតឡើងដោយធម៌ ដោយហោចទៅត្រាន់តែដុំបាយក្នុងបាត្ររបស់ខ្លួន ក៏គាប់ចិត្តចែងចែកលាភនោះៗ ដល់ពួកសព្រហ្មចារីដ៏មានសីលទាំង-ឡាយ មិនហួងហែងបរិភោគតែម្នាក់ឯង ។

## អង្គ ២ របស់ស្វា:

១ - អាស្រ័យនៅទីទីកន្លែងដូចដើមឈើធំ ដ៏ស្កប់ស្កាត់ មានមែកធាងត្រឈឹងត្រឈៃសាយពេញទៅ ជាលំនៅល្មមការពារសេចក្តីភិតភ័យរបស់ខ្លួនបាន ។

២ – ដើរក្រោកអង្គុយនៅចំពោះដូរដើមឈើណា លុះវេលាព្រលប់យប់ក៏ឈប់ដេកនៅទីដើមឈើនោះឯង ។

ប្រៀបដូចបុគ្គលដែលប្រកបដោយអង្គសម្បត្តិ ២ ប្រការ:

១ - និងនៅទីណាទីមួយ គប្បីរើសរកសេពគប់សព្រហ្មចារី ដែលមានខ្មាស មានសីលជាទីស្រឡាញ់ មានកល្យាណធម៌ ជាពហុស្សូត្រ ទ្រង់ធម៌មុខគួរស្រឡាញ់ គួរគោរព គួរសរសើរ ណែនាំប្រៀនប្រដៅឲ្យស្គាល់ល្អស្គាល់អាក្រក់ សំដែងគុណនិងទោសតាមពិតដឹកនាំក្នុងផ្លូវល្អឲ្យមានចិត្តក្លាហានរកពយក្នុងផ្លូវប្រតិបត្តិ កាលបើបានមិត្តសព្រហ្មចារីបែបនេះទើបសេពគប់ទុកជាកល្យាណមិត្តនៅអាស្រ័យជាមួយផង ។

២ – បើមុខសំដៅព្រៃណា ក៏គប្បីឈរដើរចង្ក្រម ដេក អង្គុយចំរើនសតិបដ្ឋាននៅក្នុងព្រៃនោះ ។

អង្គ ២ របស់ពូជស្រូវ:

១ – ពូជស្រូវមានប្រមាណតិច ដែលបុគ្គលព្រោះសាបទុកក្នុងស្រែមានដីជាតិល្អ មានភ្លៀងធ្លាក់ពុះមកធ្វើឲ្យជោកឫសនិងសន្ទឹកជានិច្ចពូជស្រូវនោះក៏បង្កើតផលជាច្រើន ។

២ – ពូជស្រូវដែលបុគ្គលព្រោះសាបទុកក្នុងស្រែដែលបានគាស់កនល្អហើយ រមែងដុះលូតលាស់ល្អដោយរួសរាន់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ៖

១- សីលដែលគេរក្សាល្អហើយ ជាអនុបុព្វបដិបទាដែលអាចឲ្យផលជាច្រើនតាំងអំពីមនុស្សសម្បត្តិ សម្បត្តិសួគ៌ ហើយជាបច្ច័យឲ្យបានសម្បត្តិព្រះនិព្វាន តាមសមគួរដល់ការប្រតិបត្តិនោះៗ ផង ។

២- ទប់កំរើកចិត្តទុក ទៅក្នុងទីស្ងាត់ ជម្រះចិត្តឲ្យស្អាតថ្លាដោយសតិបដ្ឋាន គឺដំកល់ចិត្តទុកឲ្យខ្ជាប់នៅក្នុង កាយ, វេទនា, ចិត្តនិងធម៌ ហើយខំសង្រួមពិចារណាឲ្យឃើញតាមសភាពពិត ទាល់តែចិត្តស្ងប់កើតបញ្ញា ជាហេតុនាំមកនូវផល ដ៏ល្អប្រពៃដោយឆាប់ដូចពូជស្រូវដែលគេបានព្រោះសាបក្នុងដីស្រែដែលមានដីជាតិល្អ ដូច្នោះ ។

## អង្គ ២ របស់ទូកគៀងក្នុងសមុទ្រ៖

១- ទូកដែលគៀងក្នុងមហាសមុទ្រ ដែលមានផ្ទៃទឹកញាប់ញ័រគឹកកងដោយរលកតូចធំក៏ជាប់ណែននៅមិនរបេះបូតទៅទិសផ្សេងៗឡើយ ។

២- អណ្តែតឡើងលើមិនបាន តែលិចស្រុតទៅក្នុងទឹកជ្រៅ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ៖

១- ទប់កំរើកចិត្តដែលមានរាគៈ ទោសៈ មោហៈ ដូចខ្សែរលកទឹកមកគ្របសង្កត់ហើយច្រើនតែធ្លាក់ទៅក្នុងអំណាចអកុសលវិតក្ក ដំកល់ចិត្តខ្ជាប់ខ្ជួនក្នុងកុសលវិតក្កទាំងឡាយមិនឲ្យរសាប់រសល់ទៅមក ។

២-កាលគ្រាមាន លាភ, យស, សរសើរ សុខ, ជាដើមក៏មិនហ៊ើង ជោរពោតាម ដល់គ្រាសាបសូន្យពាក់លាភ,យសជាដើម ក៏មិនអន់ចិត្តគប្បីតាំងចិត្តឲ្យខ្ជាប់ខ្ជួន មិនព្រួយទៅតាមអំណាចឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

## អង្គ ២ របស់ឆ្មា:

១ – សម្បើនៅក្នុងទីណាក្តី ដូចក្នុងគុហា ច្រកក្តុំបុទនិងផ្ទះសំបែង ក៏តែងតែស្វែងរកតែកណ្តុរប៉ុណ្ណោះក្នុងទីនោះៗ ។

២– ស្វែងរកអាហារស៊ីតែក្នុងទីជិតៗ ប៉ុណ្ណោះ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ:

១– ពោះនៅក្នុងទីណាៗ ជាដើម គឺក្នុងព្រៃព្រឹក្សក្តី គល់ឈើក្តី, កណ្តាលវាលក្តី ក្នុងផ្ទះស្ងាត់ក្តី គប្បីមិនប្រមាទក្នុងទីនោះៗ ចំពោះកាយគតាសតិជានិច្ច ដូចជាឆ្មាតែងស្វែងរកអាហារជានិច្ច ។

២– ចាំឧទយព្វយានុបស្សនាធម៌ជាគ្រឿងនៅ គឺឧស្សាហ៍ពិចារណាសេចក្តីកើតនិងរលត់នៃបញ្ចក្ខន្ធជាបច្ចុប្បន្ន ទាល់តែកើតបុគ្គដូងក្នុកមើលឃើញហេតុកើតនិងរលត់នៃបញ្ចក្ខន្ធនោះតាមដោយពិត ទើបបាននេះប្រើបញ្ចក្ខន្ធឲ្យជាប្រយោជន៍ អាចចាប់យកប្រយោជន៍ទាំង ៣ គឺប្រយោជន៍ក្នុងលោកនេះ ប្រយោជន៍ក្នុងលោកខាងមុខនិងប្រយោជន៍ដ៏ធំបំផុតគឺព្រះនិព្វាន ព្រោះអាស្រ័យឧទយព្វយានុបស្សនាធម៌នេះឯង ។

## អង្គ ២ របស់សត្វបបកៈ

១- បានអាហារហើយ មិនទ្រឹមស៊ីទាល់តែឆ្អែត ។

២- បានអាហារមកហើយ មិនរើសថាល្អឬអាក្រក់ ស៊ីបានទាំងអស់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការៈ

១— បានអាហារមកហើយមិនស្កប់ទ្រឹម បរិភោគតែល្មមញុំាង អត្តភាពឲ្យប្រព្រឹត្តទៅបានប៉ុណ្ណោះ ។

២— លុះបានអាហារមកហើយ មិនរើសថាល្អឬអាក្រក់ ត្រូវមាត់ឬមិនត្រូវមាត់ រមែងមានចិត្តត្រេកអរតាមមានតាមបាន ។

## អង្គ ២ របស់ជ្រូកព្រៃៈ

១- កាលដល់រដូវក្តៅ ដែលមានកំដៅខ្លាំងតែងចុះប្រឡូកនៅតែក្នុងទឹក ។

២- ប្រទះទឹកឥតភក់ល្បាប់ ក៏យកច្រមុះញីញក់ដីធ្វើឲ្យទៅជាភក់ល្បាប់ ហើយចុះដេកត្រាំ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិពីរប្រការគឺៈ

១ - កាលចិត្តកើតអផ្សុកមួម៉ៅ ក៏ចំរើនមេត្តាភាវនា ដ៏ជាធម៌ត្រជាក់ផូរផង់ ។

២- ចំរើនកាយគតាសតិខ្ជាប់មាំនៅក្នុងចិត្តហាមកំផុតអារម្មណ៍ខាងក្រៅមិនឲ្យគ្របសង្កត់ចិត្ត ។

## អង្គ ២ របស់សត្វមៀម:

១- ជាសត្រូវនឹងក្អែក វេលាយប់តែងហើរទៅរកហ្វូងក្អែកហើយ បឹកដល់ហ្វូងក្អែកពេញបន្ទុក ។

២- លាក់ខ្លួនពួនសំងំនៅក្នុងព្រៃយ៉ាងស្ងប់ ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការគឺ:

១- ជាសត្រូវនឹងអវិជ្ជា នៅក្នុងទីស្ងាត់តែម្នាក់ឯង ប្រហារអវិជ្ជាឲ្យដាច់ខាតដកបងល់ឫស ។

២- មានការគេចចេញទៅពួនសំងំជាទីត្រេកអរ ហើយពេញចិត្តទៅពួនសំងំចំរើនសមណធម៌នៅក្នុងព្រៃស្ងាត់ ។

## អង្គ ២ របស់សត្វប្រចៀវ:

១- ហើរចូលទៅក្នុងផ្ទះណាមួយហើយ ក៏ហើរចេញមកវិញ មិនមានការឡោះអាល័យនឹងផ្ទះនោះឡើយ ។

២- កាលទៅនៅនឹងផ្ទះអ្នកដទៃ មិនធ្វើឲ្យខូចខាតដល់ម្ចាស់ផ្ទះនោះឡើយ ។

របៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការគឺ:

១—ត្រាច់ទៅបិណ្ឌបាតក្នុងលំនៅផ្ទះតាមលំដាប់ច្រក ទោះបីបានក៏ដោយ មិនបានក៏ដោយ ក៏ស្រេចត្រឡប់មកវិញ មិនជាប់ចិត្តនៅនឹងផ្ទះនោះៗ ។

២—ចូលទៅកាន់ត្រកូលណាមួយ មិនបង្កសេចក្តីក្តៅក្រហាយដល់ត្រកូលនោះៗ ដូចជាហៃសុំច្រើន,ជាងពាក្យ, មិនបំផ្លាញការងាររបស់គេ, មានតែធ្វើឲ្យគេបានសេចក្តីចំរើនឡើងតាមទំនងគន្លងធម៌ ។

## អង្គ ២ របស់ព្រានសន្ទូចៈ

១ – ស្ទូចត្រីដោយសន្ទូច ។

២ – ខូចបង់នុយតែបន្តិច បានត្រីធំ ។

របៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការ គឺ:

១– បានសម្រេចសាមញ្ញផលដ៏ឧត្តមដោយញាណដែលទុកដូចជាសន្ទូចស្ទូចត្រី ។

២– លះបង់លោកាមិសដូចជានុយ ដែលជារបស់បន្តិចបន្តួចក៏បានសម្រេចនូវសាមញ្ញផលដ៏បរិបូណ៌ ។

( មានត )